BMI0023

សម្ភាសន៍ជាមួយឈ្មោះ ពេក ជឿន ភេទប្រុស អាយុ៦០ឆ្នាំ

មុខងារសម័យខ្មែរក្រហមៈ ទាហានខ្មែរក្រហម

ស្រុកកំណើតនៅភូមិកង្កែប ឃុំក្រញូប ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង

សព្វថ្ងៃរស់នៅភូមិវត្តចាស់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

១:៥៧:៣៩

សរុបទំព័រៈ ៤៥

ដានីៈ ពូអញ្ចឹងជំបូងខ្ញុំសុំស្គាល់ឈ្មោះបានទេ តើពូឈ្មោះអី?

ជឿនៈ ខ្ញុំឈ្មោះ ពេក ជឿន!

ដានីៈ ចុះឈ្មោះពូពីកំណើត ពីឪពុកម្ដាយដាក់ឲ្យ?

ជឿនៈ ឈ្មោះកែវ សារឿន!

ដានីៈ កែវ សារឿន?

ជឿនៈ បាទ!

ដានីៈ សព្វថ្ងៃពូអាយុប៉ុន្មានហើយ?

ជឿនៈ ៥៩តែចូលឆ្នាំនេះខ្ញុំ៦០ហើយ!

ដានីៈ ពូមានស្រុកកំណើតនៅភូមិឃុំអីដែរ?

ជឿនៈ ស្រុកកំណើតខ្ញុំនៅភូមិកង្កែប ឃុំក្រញូប!

ដានីៈ ស្រុក?

ជឿនៈ ស្រុកកំពង់លែង!

ដានីៈ ខេត្តកំពង់ឆ្នាំង?

ជឿនៈ បាទ!

ដានីៈ ឪពុកម្ដាយពូគាត់ឈ្មោះអីដែរ?

ជឿនៈ គាត់ស្លាប់អស់ហើយ!

ដានីៈ អត់ទេខ្ញុំសុំស្គាល់ឈ្មោះគាត់បានទេ?

ជឿនៈ ឪពុកខ្ញុំឈ្មោះ ជួន!

ដានី៖ ឪពុកឈ្មោះ ជួន?

ជឿន៖ បាទ!

ដានី៖ ម្ដាយ?

ជឿន៖ ម្ដាយឈ្មោះ ណែម!

ដានី៖ គាត់ស្លាប់តាំងពីអន្កាល់?

ជឿន៖ អ៎ម្ដាយស្លាប់យូហើយ! តាំងពីឆ្នាំ៦៦ម្លេះ ដល់ពេលឪពុកខ្ញុំតាំងពី៧៦ ។

ដានី៖ ឆ្នាំ៧៦ហ្នឹងគាត់ស្លាប់ដោយសារមូលហេតុអី?

ជឿន៖ ស្លាប់ដោយសារជំងឺ!

ដានី៖ ពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

ជឿន៖ ច្រើននាក់ណាស់ជាង១០!

ដានី៖ អ៎! ច្រើនណាស់ ប៉ុន្ដែឪពុកពូគាត់មានប្រពន្ធពីរ?

ជឿន៖ ប្រពន្ធពី!

ដានី៖ ចុះបងប្អូនបង្កើតរបស់ពូមានប៉ុន្មាននាក់?

ជឿន៖ មាន៨នាក់!

ដានី៖ ពូកូនទីប៉ុន្មាន?

ជឿន៖ ខ្ញុំកូនទី៣!

ដានី៖ កូនទី៣?

ជឿន៖ បាទ!

ដានី៖ ស្រីប៉ុន្មានប្រុសប៉ុន្មានបងប្អូនរបស់ពូ៨នាក់ហ្នឹង?

ជឿន៖ ស្រី៣នាក់ ប្រុស៥នាក់!

ដានី៖ ស្រី៣នាក់ ប្រុស៥នាក់?

ជឿន៖ បាទ! ហើយថែមចុងទៀតបាន៥នាក់ទៀត!

ដានី៖ សព្វថ្ងៃពូរស់នៅក្នុងភូមិអីដែរ?

ជឿន៖ ភូមិវត្តចាស់!

ដានី៖ ឃុំអី?

ជឿន៖ ឃុំម៉ាឡៃ!

ដានី៖ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ?

ជឿនៈ បាទ!

ដានីៈ គ្រួសារពូគាត់ឈ្មោះអីដែរ?

ជឿនៈ ឈ្មោះ ប៊ូ ភុត!

ដានីៈ គាត់អាយុប៉ុន្មានហើយ?

ជឿនៈ អាយុ៥៥ហើយម៉ែវា!

ដានីៈ ពូមានកូនចៅប៉ុន្មាននាក់ដែរ?

ជឿនៈ កូន៥នាក់!

ដានីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ជឿនៈ ស្រីមួយ ប្រុស៤!

ដានីៈ កូនពូធំៗអស់ហើយ?

ជឿនៈ ធំៗអស់ហើយ!

ដានីៈ បងអាយុប៉ុន្មានហើយ?

ជឿនៈ បងអាយុ៣១ហើយ!

ដានីៈ ចុះពៅគេ?

ជឿនៈ ពៅគេអាយុ២០!

ដានីៈ អាយុ២០ អញ្ចឹងធំអស់ហើយ!

ជឿនៈ បាទ!

ដានីៈ អញ្ចឹងខ្ញុំចង់ដឹងពីប្រវត្តរបស់ពូបានទេ កាលពីយើងបែក៧៩ពេលដែលយួនចូលម៉ោដល់ភ្នំពេញ កាលហ្នឹងពូយ៉ាងម៉េចដែរ ពូអាចជួយរៀបរាប់ពីជីវិតរបស់ពូបានទេតាំងពី៧៩ម៉ោ?

ជឿនៈ តាំងពី៧៩ម៉ោខ្ញុំធ្វើទាហានរហូតហ្នឹង ខ្ញុំទាហានវ៉ៃផងរត់ផង!

ដានីៈ រត់ពីណាម៉ោតាំងពីដំបូងម៉ោ ដំបូងដូចថាពូធ្វើទាហាននៅណា ហើយបែក៧៩ហ្នឹងពូបែកពីកន្លែងណាទៅកន្លែងណា?

ជឿនៈ ដំបូងខ្ញុំនៅកន្លែងសាលអន្តរជាតិ!

ដានីៈ សាលអន្តរជាតិ?

ជឿនៈ បាទ! ចប់ពីសង្គ្រាមបីឆ្នាំម៉ោខ្ញុំនៅផ្សារថ្មីអាផ្ទះ៧ជាន់ហ្នឹង!

ដានីៈ បាទ!

ជឿនៈ កន្លែងហ្នឹងគេធ្វើជាចំការលក់ឲ្យបរទេស ហើយខ្ញុំនៅលក់ដូរនៅទីហ្នឹងឯង! ដល់ពេលសភាពការណ៍មិនស្រួលចេះតែរត់ទៅ! គេកែប្រែគេរវល់កងទ័ពគេបិទទីផ្សារគេបើកផ្លូវចេញម៉ោហ្មង! គេវ៉ៃគ្នាតាំងពីក្នុងភ្នំពេញម៉ោរហូត ហើយនៅខាងផ្នែកក្រសួងការបរទេសហ្នឹងគេរៀបចំកងទ័ព មានមេឈ្មោះហុងនេះ!

ដានីៈ ស៊ឺហុង?

ជឿនៈ តូ ហុង!

ដានីៈ តូ ហុង?

ជឿនៈ បាទ!

ដានីៈ កាលហ្នឹងគាត់នៅក្រសួងកាបរទេសដែរ?

ជឿនៈ បាទ! ក្រោមការដឹកនាំរបស់តាអៀង សារី ទាំងអស់!

ដានីៈ បាទ!

ជឿនៈ មួយកងពលហ្មងណាស់!

ដានីៈ ហើយយ៉ាងម៉េចទៀតទៅ?

ជឿនៈ វ៉ៃគ្នានៅកន្លែងថ្នល់ទទឹងយើងហ្នឹងពេទ្យលោកសង្ឃ ហើយទៅទួលគោកម៉ោលិចម៉ោតាមពេទ្យចិន!

ដានីៈ ម៉ោតាមពេទ្យចិន?

ជឿនៈ បាទ! កាលហ្នឹងមិនបានដើរស្រួលដូចគេទេណា៎ព្រោះយើងកងទ័ព ហើយម្យ៉ាងទៀតកងទ័ពវៀតណាមចេះតែដេញម៉ោ វ៉ៃគ្នាផងអីផងរហូតម៉ោដល់ភូមិថ្មីដងទង់ហ្នឹង! វ៉ៃគ្នាបានជិតមួយខែដែរបានក្រោយម៉ោតាម៉ុកកងទ័ពផ្នែកក្រសួងការបរទេសគេយកមកសម្ងួត ប៉ុន្តែមិនបានមកដល់សម្ងួតទេម៉ោដល់ត្រឹមកងក្រឡូ ដល់ពេលដល់កងក្រឡូចុះដើរហ្មង ព្រោះកងទ័ពវៀតណាមបិទផ្លូវ ហើយឡានអីត្រូវទម្លាក់ចោលនៅត្រឹមកោះក្រឡូ ហើយក៏ចាប់ដើរឡើងមកនេះវិញ ដំណើរយើងដំណើរកងទ័ពវា៣-៤-៥ពាន់ដែរមិនសូវខ្លាចអ្នកណាដែរ គ្រាប់មានដែរ

ដានីៈ អ៊ូ!គ្នាច្រើនដែរ?

ជឿនៈ បាទ!ពេលហ្នឹងពួកខ្ញុំមាននារី៦០០០នាក់នោះ នារីផ្សារអូរឫស្សី! ហើយពួកខ្ញុំ៣,៤ពាន់នាក់ហ្នឹងទៅកើតនោះទៅការពារស្រីៗ ហើយណាមួយគេថាទិសដៅយកមកលិចដើម្បីម៉ោព្រំដែន!

ដានីៈ ក្រសួងការបរទេសហ្នឹងធំអញ្ចឹង?

ជឿនៈ កម្លាំងធំដែរហ្នឹងព្រោះច្រើនដែរ! គេមិនចាប់អារម្មណ៍អារឿងខ្មែរបះបោលអីទេ គេចាប់អារម្មណ៍តែរឿងកងទ័ពវៀតណាមឈ្លានពានទេណា៎!

ដានីៈ បាទ!

ជឿនៈ ដូចខ្ញុំជម្រាបដាក់ស្ដែងអញ្ចឹងគេចាប់បានយួនទាំងរយៗ!

ដានីៈ កងទ័ពយួនមានគេចាប់បានដែរ?

ជឿនៈ ចាប់បាន! ប៉ុន្តែមិនបានជាធ្វើអីទេមើលទៅ ដូចថាយើងចាប់ទៅមិនបានជាមានកន្លែងឃុំឃាំងអីទេណា៎ ដល់ពេលយកមកទុកមួយជុំអញ្ចឹងគេវ៉ៃវិញ! ហើយកងទ័ពវាតាមវ៉ៃដែរហ្នឹង ដល់ពេលវ៉ៃយើងមិនបានគិតទេទៅណាទៅយើងរត់យកតែខ្លួនដែរព្រោះកាលនោះខាងលើពួកខ្ញុំគេមាននយោបាយមួយថា យើងប្រើងទប់ស្កាត់ដើម្បីការពារកម្លាំង អត់មានយកឈ្នះចាញ់ទេធ្វើម៉េចយើងទប់ផងស្កាត់ផងហើយបានដំណើរនោះបានកាន់តែទៅខាងលិចឆ្ងាយ!

ដានីៈ ហើយម៉េចទៀតទៅ?

ជឿនៈ គិតទៅដំណើរមួយខែចេញពីកន្លែងគេហៅបាតបឹងម៉ោឆ្លងតាមពោធិ៍សាត់ម៉ោមួយខែបានដល់ព្រំដែន! ដល់យើងនៅខ្លែមកំរៀងនេះធ្វើដំណើរមួយខែ!

ដានីៈ យ៉ាងម៉េចដែរពេលនៅខ្លែមកំរៀង?

ជឿនៈ នៅហ្នឹងមានដូចថាមូលដ្ឋានរបស់ព្រំដែនដូចថាគេទាក់ទងថៃបាន អាហ្នឹងដកកម្លាំងចេញម៉ោក្រោយអស់ហើយ ចាប់រៀបកងទ័ពដើម្បីតទល់ទៅវិញហ្នុង!

ដានីៈ ចុះស្រីៗគេឲ្យទៅនៅណាទៅ?

ជឿនៈ គេឲ្យនៅតាមព្រំដែនហ្នឹងឯង ចាប់ដាកម្លាំងដឹកជញ្ជូនវិញ!

ដានីៈ ចាប់ដាកម្លាំងដឹកជញ្ជូនវិញ?

ជឿនៈ បាទដោយមានម្ចាស់ការមានមេស្រីគេ មានប្រដាប់អាវុធខ្លួនគេការពារ!

ដានីៈ ពីណាគេមេស្រីហ្នឹង?

ជឿនៈ ពីមុនស្គាល់ដែរតែឥលូវវាបែកគ្នាអស់ហើយ វាចាស់ដូចគ្នា ពីមុនមានមេគេនៅ ប៉ុន្តែពីមុនមានមិត្តអេងអីគេទៅខាងត្បូង ហើយនៅនេះក៏មានដែរដូចខ្ញុំអីក៏មានដែរ គេនេះក៏ធ្លាប់មេដែរហើយនៅខាងខ្លាងរាប់នោះមួយដែរ អាហ្នឹងមេនារីៗដែលគេដឹកជញ្ជូនណា៎!

ដានីៈ នារីកាលហ្នឹងច្រើនទេ?

ជឿនៈ ច្រើន! រាប់ម៉ឺនដែរហ្នឹង អាហ្នឹងគេហៅថាអង្គភាពកាត់ដេរ រដ្ឋគេនៅផ្សារអូរឫស្សីហើយក្រសួងការបរទេស!

ដានី៖ កាត់ដេររដ្ឋហើយនឹងក្រសួងការបរទេស?

ជឿន៖ អត់ទេកាត់ដេររដ្ឋហ្នឹងកាលហ្នឹងជារួមទេ ក្រសួងកាត់ដេរគេនៅកន្លែងផ្សារអូរឫស្សី ហើយក្រសួងការបរទេសនេះក៏មានមួយពាន់ពីពាន់ដែរ! ហើយរដ្ឋចេះតែប្រមូលគ្នាម៉ោជាបន្តបន្ទាប់!

ដានី៖ អញ្ចឹងដល់ពេលនៅព្រំដែនហ្នឹងនារីធ្វើកងដឹកជញ្ជូននៅតាមព្រំដែន?

ជឿន៖ បាទ!

ដានី៖ ពីត្រឹមណាដល់ត្រឹមណាទៅ?

ជឿន៖ គិតទៅម៉ោបណ្ដោយព្រំដែន បើតាមខ្ញុំរៀបចំនៅខ្សែមកំរៀងវាហូតព្រំដែនម៉ោទល់យើងត្រឹមនោះ ដល់ពេលពីហ្នឹងម៉ោនេះវាមានអង្គភាពគេផ្សេងម៉ោតពីនេះទៀត!

ដានី៖ ចុះពូកាលហ្នឹងគេបែងចែកនារីនៅខាងដឹកជញ្ជូនហើយប្រុសធ្វើកងទ័ព?

ជឿន៖ បាទ!

ដានី៖ កងទ័ពនៅណាទៅ?

ជឿន៖ កងទ័ពយើងឡើងទៅខាងមុខទៅទប់ស្កាត់ការពារកម្លាំង ដូចថាគេចែកមុខសញ្ញាវាមានវ័ណ្ឌគ្នាអញ្ចឹងណា៎!

ដានី៖ អាហ្នឹងនៅកំរៀងឬក៏នៅណា?

ជឿន៖ ពីមុនខ្ញុំនៅប្រា ដល់ចេញពីប្រាម៉ោមកនៅជំរុំបានមួយភ្លែត ដល់ឆ្នាំ៧១បានចេញ កាល៧៩ហ្នឹងចូលជំរុំបានប៉ុន្មានខែតើព្រោះឈឺ!

ដានី៖ ឈឺអីគេ?

ជឿន៖ គ្រុនចាញ់!

ដានី៖ ចូលជំរុំណាទៅ?

ជឿន៖ ចូលជំរុំកាន់ពុត!

ដានី៖ ជំរុំកាន់ពុត?

ជឿន៖ បាទ!

ដានី៖ អាហ្នឹងនៅណានៅក្នុងដីយើងមែន?

ជឿន៖ អត់ទេនៅក្នុងដីថៃនៅពីក្រោយប៉ៃលិនយើងនេះ!

ដានី៖ អញ្ចឹងពូសម្រាកនៅជំរុំបានរយៈពេលប៉ុន្មានទៅ?

ជឿន៖ មិនបានមួយឆ្នាំស្រួលទេព្រោះយើងទៅ៧៩ខែ១១ហើយ៨១យើងចេញម៉ោវិញ!

ដានី៖ កាលហ្នឹងមានពេទ្យទេ?

ជឿនៈ ពេទ្យច្រើនណាស់!

ដានីៈ ជំងឺច្រើនដែរ?

ជឿនៈ ជំងឺក៏ច្រើន!

ដានីៈ សុទ្ធតែជំងឺគ្រុនចាញ់មែន?

ជឿនៈ បាទ!

ដានីៈ ចុះពូកាលហ្នឹងកងទ័ពមានឈឺទេ?

ជឿនៈ មានឈឺតើ!

ប្រពន្ធៈ គាត់មាននៅទ័ពណា!

ជឿនៈ ដឹកជញ្ជូនមួយភ្លែតហ្នឹង!

ដានីៈ ដឹកជញ្ជូនពេលណា?

ជឿនៈ ដឹកជញ្ជូនពេលដែលគេរៀបចំកងនារីមួយភ្លែតហ្នឹង!

ដានីៈ ដល់ពេលបកម៉ោវិញម៉ោនៅណា?

ជឿនៈ ម៉ោនៅភូមិដូង!

ដានីៈ ម៉ោនៅភូមិដូង?

ជឿនៈ បាទ! ហើយគេឲ្យនៅកសាងសាលាយោធាបានបីបួនឆ្នាំដែរ ខ្ញុំធ្វើនៅមន្ទីរក្នុងហ្នឹងធ្វើសាលាយោធាហើយធ្វើផ្ទះសម្តេចតា!

ដានីៈ ពូធ្វើជាងវិញ?

ជឿនៈ បាទ!

ដានីៈ កាលហ្នឹងពូរៀបការជាមួយមីងនូវ?

ជឿនៈ ខ្ញុំរៀបការតាំងពីនៅជំរុំកាលជួបគ្នានៅជំរុំ!

ដានីៈ កាលជួបជាមួយមីងនៅជំរុំហ្នឹងនៅឆ្នាំណា?

ជឿនៈ នៅឆ្នាំ៨០!

ដានីៈ កាលហ្នឹងពូនៅឈឺនៅឡើយ?

ជឿនៈ អត់ទេជាហើយ ជាហើយរកក្រឡាម៉ោវិញហ្នឹងវាអត់ទាន់ទាក់ទងពីណាគេបាន! ដល់ជួបគ្នារៀបការហ្នុងទៅ!

ដានីៈ ពូមានដែលបានជួបគ្នាអត់?

ជឿនៈ អត់ទេ អត់ដែលស្គាល់គ្នាទេ!

ដានី៖ អញ្ចឹងស្គាល់គ្នានៅជំរុំ?

ជឿន៖ បាទ!

ដានី៖ កាលហ្នឹងម៉េចទៅបានពូស្គាល់គ្នាហើយបានរៀបការជាមួយគ្នា?

ជឿន៖ សុំច្បាប់ថៃ គេមិនឲ្យយើងយកគ្នាផ្តេសផ្តាស់ដែរហ្នឹង! គេសុទ្ធតែកត់កន្លែងដែលគេហៅចល័តគេនោះ គេគ្រប់គ្រងការពារយើងក្នុងជំរុំនោះ គេឲ្យសុំច្បាប់គេ គេហៅយើងតែពីនាក់ទៅសួសម្ភាសន៍ពិនិត្យសុខភាពអីស្រួលបួល ហើយគេសួទាំងស្រីទាំងប្រុសមិនឆ្លើយមិនបាន តែស្រីថាអត់ស្រលាញ់គេអត់ឲ្យការ!

ដានី៖ កាលហ្នឹងពូអាយុប៉ុន្មាន?

ជឿន៖ អាយុ២៧ឆ្នាំ!

ដានី៖ ចុះមីង?

ជឿន៖ អាយុ២២!

ដានី៖ កាលហ្នឹងយើងរៀបការតាមប្រពៃណីខ្មែរយើងឬក៏?

ជឿន៖ តាមប្រពៃណីខ្មែរយើង!

ដានី៖ រៀបការតែមួយគូឬក៏ច្រើនគូ?

ជឿន៖ បើយើងចង់យកច្រើនគូទាល់តែធ្វើតាមកម្ពុជាប្រជាធិបតេយ្យមុន តែដល់ពេលយើងទៅនោះវាផ្សេងហើយ! មិនអាចបានច្រើនទេបានតែមួយគូ ប៉ុន្តែយើងមិនបានធំដុំទេគ្រាន់ថាមានចាស់ទុំ ហើយមានផ្លែឈើនំនែកអី ហើយមានមនុស្សប្អូនដប់ម្ភៃនាក់អីចឹងណា៎! យើងហៅអ្នកណាដែលយើងស្គាល់គ្នាប្រមែលប្រមូលចាស់ទុំខាងប្រុសខាងស្រីជាតំនាងម៉ែឪ!

ដានី៖ ចុះកាលហ្នឹងម៉េចបានមីងទៅជំរុំដែរ?

ជឿន៖ ខ្ញុំឈឺគាត់ឈឺដែរ!

ដានី៖ ពូក៏ឈឺមីងក៏ឈឺ?

ជឿន៖ តែនៅអង្គភាពផ្សេងគ្នា! ខ្ញុំគេសែងយកទៅដាក់នៅហ្នឹង ហើយមីងក៏គេយកទៅដាក់ហ្នឹងដែរ! មិនដែលឃើញគ្នាទេដល់ពេលជាបានដើរលេងទៅជួបគ្នា!

ដានី៖ កាលឈឺនៅផ្សេងគ្នាដល់ពេលជាបានដើរទៅជួបគ្នា?

ជឿន៖ ដើរលេងនោះព្រោះអផ្សុក ហើយស្រីៗគ្នាពួននៅតែក្នុងផ្ទះដែរហ្នឹងដល់ពេលប្រុសគ្មានខ្លាចអីចេះតែដើរប្អូនប្រាំនាក់!

ដានី៖ ចុះមានគេជួបគ្នាបានរៀបការច្រើនទេ?

ជឿនៈ ច្រើន!

ដានីៈ កាលហ្នឹងម៉េចបានមីងទៅនៅជុំរុំទៀត?

ជឿនៈ អ្នកនៅម៉ាឡៃស្រុកខ្ញុំកាលហ្នឹងខ្ញុំដឹកនាំដែរហ្នឹង! គេឃើញយើងទៅគេទៅយកម៉ោវិញមកធ្វើការងារ ហើយខ្ញុំបើនិយាយខ្ញុំទៅបើដូចសម័យនេះគេធានាយកទៅក្រៅដែរហ្នឹង អូស្ត្រាលីក៏ចង់បានយកទៅតែដូចជាវាគ្មានពេល ហើយប្រពន្ធខ្ញុំឈឺងរាល់តែថ្ងៃហ្នឹង!

ដានីៈ អ្នកណាអ្នកធានា?

ជឿនៈ ប្អូនខ្ញុំ ចន្ទសួខ្ញុំជាបងខ្ញុំយកគេហើយ ដល់ហើយខ្ញុំថាយកទៅបើងាប់ៗក្នុងព្រៃទាំងអស់គ្នាហើយគេបានប្តីនៅអូស្ត្រាលីគេស្រួលទៅ តែមួយថ្ងៃមិនដែលទាក់ទងគ្នាបានទេ គេភ្លេចឯងហើយមិនដឹង! មាននៅមួយនៅសហរដ្ឋគ្រាន់ចិញ្ចឹមម៉ែវា គេស្រាវជ្រាវរហូតទាល់តែឃើញខ្ញុំនៅកន្លែងនេះគេបានម៉ោដេកនៅផ្ទះខ្ញុំម្តងដែរ!

ដានីៈ អ៊ំបានម៉ោដែរ?

ជឿនៈ ម៉ោទាំងប្តីទាំងប្រពន្ធ! ប្រពន្ធគេហ្នឹងគេនៅរកទាក់រាប់អានគាត់មែន ទើបតែដាច់លេខទូរស័ព្ទប៉ុន្មានខែទើបលែងបានទាក់ទងគ្នា!

ដានីៈ ចុះពូដល់ពេលយើងត្រលប់ម៉ោនៅកន្លែងភូមិដូនវិញយ៉ាងម៉េចដែរ ពូអាចរៀបរាប់បានទេ?

ជឿនៈ ពេលដែលខ្ញុំត្រលប់ម៉ោនៅភូមិដូនវិញចាប់ផ្តើមធ្វើទាហានម្តង!

ដានីៈ កាលហ្នឹងនៅក្នុងកងពលណា?

ជឿនៈ នៅក្នុងកងពល៤៥០!

ដានីៈ នៅជាមួយតាភាពអីហ្នឹង?

ជឿនៈ បាទ! នៅជាមួយដូចជាតាផុនអីហ្នឹង!

ដានីៈ តាផុននោះគាត់ស្លាប់ពេលណាដែរ?

ជឿនៈ គាត់ស្លាប់តាំងពីយើងទើបតែម៉ោពីនេះ គាត់ស្លាប់យូហើយតាំងពីឆ្នាំ៨១!

ដានីៈ ចុះកាលហ្នឹងពូនៅខាងវរៈណាដែរ?

ជឿនៈ ខ្ញុំនៅវរៈ១០៦!

ដានីៈ វរៈសេនាតូច១០៦?

ជឿនៈ វរៈសេនាធំតើ!

ដានីៈ អ៊ំ!

ជឿនៈ នៅក្នុងហ្នឹងវាមានប៉ុន្មានវរៈទៀតនោះ! មាន២១,២២,២៣!

ដានី៖ កាលហ្នឹងកងទ័ពប៉ុន្មានទៅ?

ជឿន៖ ច្រើនដែរ! បីបួនពាន់ដែរ!

ដានី៖ កាលហ្នឹងពូទទួលវរៈសេនាតូចលេខប៉ុន្មានដែរ?

ជឿន៖ លេខ២២!

ដានី៖ វរៈសេនាធំលេខប៉ុន្មាន?

ជឿន៖ ១០៦!

ដានី៖ អ្នកណាគេទទួលខាងវរៈសេនាធំ?

ជឿន៖ រស់ សារ៉េត ជា ទូម អីហ្នឹង! តែលូវគេកាត់អស់ហើយនៅតែខ្ញុំទេមិនទាន់កាត់ គេគ្រាន់តែត្រៀមពេលណាគេហៅចូលទៅ! ប៉ុន្តែខ្ញុំនៅខេត្តនោះខ្ញុំ!

ដានី៖ នៅបន្ទាយមានជ័យមែន?

ជឿន៖ បាទ!

ដានី៖ កាលហ្នឹងទាហានមានប៉ុន្មានកងពល កាលនៅម៉ាឡៃមានកងពលអីគេ?

ជឿន៖ កងពល៤៥០!

ដានី៖ ៤៥០?

ជឿន៖ បាទ!

ដានី៖ ចុះខាងសំពៅលូន?

ជឿន៖ ខាងសំពៅលូនមានប៉ុន្មានទេ? សំពៅលូនគេច្រើនគេឡើងពីកងពលហើយ!

ដានី៖ ចុះខាងប៉ៃលិនអី?

ជឿន៖ ប៉ៃលិនគេផ្សេង អានេះតាកនផ្សេង!

ដានី៖ បាទតាកនខាងសំពៅលូន!

ជឿន៖ បាទ!

ដានី៖ ចុះអ្នកគ្រប់គ្រង?

ជឿន៖ កាលមុនហ្នឹង?

ដានី៖ បាទ!

ជឿន៖ បើក្នុង៤៥០នេះវាមានអៀង សារី បើខាងតាកនោះមានស៊ុន សេន តាអៀង សារីគាត់មានពីកងពលខាងខ្ញុំម៉ាឡៃ៤៥០ផងហើយខាងនោះផង!

ដានី៖ បាទ!

ជឿនៈ ហើយខាងសុន សេន នោះគាត់ខាងជើងនោះ ដល់តពីប៉ៃលិនទៅត្បូងទៀតអាហ្នឹងខាងតា នួន ជា!

ដានីៈ ខាងតា នួន ជា?

ជឿនៈ បាទ!

ដានីៈ ចុះតាម៉ុក?

ជឿនៈ តាម៉ុកខាងជើង!

ដានីៈ ប៉ុន្តែគាត់អាសាជួបពូទេ?

ជឿនៈ គាត់អាសាម៉ោតើ!

ដានីៈ អាសាម៉ោ?

ជឿនៈ ពេលសម្តេចតាយាងម៉ោហើយតាៗគាត់ម៉ោដែរ!

ដានីៈ កាលសម្តេចយាងម៉ោនៅឆ្នាំណា?

ជឿនៈ គាត់ម៉ោបីដងហើយ! គ្រាន់តែថាគាត់យាងម៉ោខ្ញុំមិនសូវចំនាំទុកឆ្នាំទេគ្រាន់តែដឹងថាម៉ោបីដងហើយ!

ដានីៈ កាលពូមានតួនាទីអីទេ?

ជឿនៈ អត់ទេខ្ញុំអត់មានតួនាទីអីទេ គ្រាន់តែជាអ្នកទទួល!

ដានីៈ កាលសម្តេចម៉ោហ្នឹងយ៉ាងម៉េចដែរពូ?

ជឿនៈ ម៉ោឡានតាមដីថៃហ្នឹងចូលកន្លែងយើងផ្សាហ្នឹងឯង!

ដានីៈ ពីណាខ្លះម៉ោទទួលសម្តេច?

ជឿនៈ ម៉ោហ្នឹងមានពួកយើងខាងព្រៃហ្នឹង! ដូចថាម៉ោស្រុក៨៥០អញ្ចឹងកងទ័ព៨៥០ហ្នឹងម៉ោការពារ!

ដានីៈ យ៉ាងម៉េចទៅស្ថានភាពពេលហ្នឹង?

ជឿនៈ កាលហ្នឹងវាអត់មានអីតឹងរឹងដែរទេ! បើនិយាយពីយើងជីវភាពអន្តរអីចឹងក៏អត់សូវខ្វះដែរ ព្រោះវាមានគេហៅឡានកាកបាទគេ គេម៉ោជួយដែរណា៎!

ដានីៈ បាទ!

ជឿនៈ ខ្ញុំដឹងតែគេដាក់សញ្ញាពេទ្យដឹងតែកាកបាទហើយ!

ដានីៈ កាកបាទ?

ជឿនៈ ព្រោះពួកហ្នឹងគេអាញ៉ាកណ្តាល ។

ដានីៈ កាលហ្នឹងដូចថាជីវភាពកងទ័ព ជីវភាពប្រជាជនហើយនឹងកងនារីៗ អីហ្នឹងបានហូបចុកគ្រប់គ្រាន់ដែរ?

ជឿនៈ បរបូ!

ដានីៈ បរបូ?

ជឿនៈ បាទ!

ដានីៈ អញ្ចឹងយើងបានកាកបទក្រហមជាជំនួយតែម្តង?

ជឿនៈ គេបើកម៉ោហ្នឹង ហើយខាងនេះក៏គេទិញទុកដែរ!

ដានីៈ អ៊ំ យើងទិញម៉ោពីថៃម៉ោ?

ជឿនៈ បាទ! ហើយកាកបទហ្នឹងគេម៉ោម្តងបីបួនប្រាំឡាននោះ បើតាមខ្ញុំដឹងក្នុងមួយឡានមាន៤០០បាវនោះ អាឡានកង់ដប់ហ្នឹង!

ដានីៈ បាទ!

ជឿនៈ គេម៉ោជួយនោះផ្សេង ហើយគេម៉ោចែកឲ្យប្រជាជននោះផ្សេងកាលហ្នឹង ប៉ុន្តែខ្មែរក្រហមវាលេងល្បិចខូចដែរហ្នឹងកាលហ្នឹងដូចថាបន្ទិលក្រឡាអត់ឲ្យដឹងទេ! គេថាគេចង់ដឹងថាមនុស្សប៉ុន្មាននាក់ ហើយរាប់ប៉ុន្មានថ្ងៃក៏អត់អស់!

ដានីៈ គេបន្ទិលពីកន្លែងហ្នឹង?

ជឿនៈ បន្ទិលហ្នឹង វិលហ្នឹងទោះយើងយកអីមកលាបបិទក៏នៅតែមិនអាចនេះទេ គេមានវិធីបោសសម្អាតឲ្យស្អាតមិនឲ្យស្គាល់ហ្នឹង ផ្លាស់ប្តូរតាំងពីសម្លៀកបំពាក់អត់ឲ្យដឹងទេស្មានតែមនុស្សថ្មីរហូត ដល់ពេលវាច្រើនពេកខ្ជិលរាប់កើតជារបស់ហ្នឹងដឹកទាំងឡានទៅដល់បោះទម្លាក់តាមដែលយើងចាត់ចែងហ្នឹង!

ដានីៈ អញ្ចឹងកាលហ្នឹងរបស់របរហូបចុកអីមិនខ្វះទេ?

ជឿនៈ មិនខ្វះទេ! និយាយរួមតាំងពីខ្ញុំមកនៅនេះ៨១នោះមានទាំងត្រីខ បើកាល៧៩យើងរត់នោះវាយ៉ាប់ហ្នឹងឯងព្រោះរត់ទាំងគេទាំងឯងដូចខ្ញុំថាអញ្ចឹងមួយខែហ្នឹងវាតឹងតែងដែរ!

ដានីៈ បាទ! ចុះដូចថាយើងកងទ័ពយុវជនឬក៏កងដឹកជញ្ជូនអីមានបង្ករបង្កើនផលទេ?

ជឿនៈ មានដាំបន្លែ! ហើយបន្លែហ្នឹងមិនបានលក់ដូរទេគ្រាន់ថាហូបមិនអស់ទេ មានស្ពៃក្តោបមានអី!

ដានីៈ យើងដាំដែរ?

ជឿនៈ ដាំ! ស្ពៃក្តោប ឆៃថាវ មានដាំគ្រប់មុខ មានត្រកួន ត្រលាច ល្ពៅ!

ដានីៈ សុទ្ធតែយើងដាំ?

ជឿនៈ បាទ!

ដានីៈ ដាំនៅកន្លែងណាទៅ?

ជឿនៈ តាមបណ្ដោយមាត់អូរ!

ដានីៈ កាលហ្នឹងគេហៅតែភូមិដូងហ្នង?

ជឿនៈ បាទ!

ដានីៈ ម៉េចបានគេហៅភូមិដូងអញ្ចឹង?

ជឿនៈ វាមានចំការដូងនៅក្បែ!

ដានីៈ ចំការដូងរបស់ថៃមែន?

ជឿនៈ បាទ! នៅថៃ

ដានីៈ អញ្ចឹងគេហៅភូមិដូងទៅ?

ជឿនៈ បាទ! យើងមិនដឹងដាក់ឈ្មោះថាម៉េចក៏ដាក់ឈ្មោះភូមិដូងហ្នងទៅ!

ដានីៈ ចុះកាលហ្នឹងពេលដែលពូម៉ោដល់ម៉ាឡៃដំបូងពូឃើញទិដ្ឋភាពនៅម៉ាឡៃហ្នឹងយ៉ាងម៉េចដែរ? ដូចថាម៉ោដល់ឃើញភូមិស្រុកហើយនឹងព្រៃហ្នឹងយ៉ាងម៉េចដែរ?

ជឿនៈ ម៉ោដល់ឃើញព្រៃសុទ្ធហ្នង! ព្រៃវាមានដូចតាមបណ្ដោយអូរនេះព្រៃនេះ ដល់ពេលទៅត្រឹមវត្តទៅនោះព្រៃឫស្សី ឫស្សីហ្នឹងវាកើតផ្លែនៅឆ្នាំណាទេដល់ហើយងាប់អស់អាលីងចេញព្រៃម៉ោវិញ បើតាមនេះឈើធំៗណាស់ ពិសេសផ្សារតាំងហ្នឹងកាត់មួយដើមសុទ្ធតែយកស្មឹចងទាញខ្លាចដួលកិន!

ដានីៈ ចុះកាលពីមុនម៉ោមានព្រៃមានឈើអីទេ?

ជឿនៈ មានឈើធំៗ មានឈើស្រឡៅ ឈើបេង ឈើគគី ប៉ុន្តែគេកាត់ហើយ!

ដានីៈ គេកាត់ពេលយើងម៉ោនៅ!

ជឿនៈ គេកាត់គេមានម៉្យាងដែរ ម៉្យាងភាគច្រើនយើងខ្វះគេដឹងរឿងចាយលុយចាយអីនោះ!

ដានីៈ អញ្ចឹងដូនកាលយើងកាប់ដោះដូរទៅ ហើយដូនកាលយើងធ្វើផ្ទះធ្វើអីទៅ!

ជឿនៈ អារឿងផ្ទះហ្នឹងធ្វើក្រោយទេ អញ្ចឹងវាអស់ឈើល្អហើយ ហើយកាលនោះយើងដោះស្រាយដែរព្រោះខាងលើមិនមានថវិការបើកទេមានតែអង្ករ ប៊ីចេង ថ្នាំពេទ្យ សម្លៀកបំពាក់អីទេ ដល់ពេលថវិការចាយអត់មាន ព្រោះយើងនៅជិតថៃគេចាយលុយដល់អញ្ចឹងមានតែអារឈើហ្នឹងហើយ!

ដានីៈ អញ្ចឹងពូកាលហ្នឹងយើងធ្វើតែព្រៃទេ?

ជឿនៈ ធ្វើព្រៃ!

ដានីៈ កាប់ឆ្ការកាប់អីចឹងទៅ?

ជឿនៈ បាទ! ពីសង្គ្រាមវាល្អមអស់ហើយ ហើយក្រោយសរមារ៉ែនកម្មបានលែងមែនទែនហ្នឹងទាំងចំការ ទាំងឈើអារលក់! កាលយើងនៅសង្គ្រាមយើងគ្រានតែចោះៗព្រោះរស់នៅបណ្ដោយអូរព្រំដែនរហូតទៅទល់យើងខ្លាងាប់!

ដានីៈ ខ្លាងាប់នៅម្ដុំណា?

ជឿនៈ ខ្លាងាប់ចេញពីផ្លូវ៥០២ម៉ោដែលយើងម៉ោពីម៉ក់ហីនម៉ោអញ្ចឹងម៉ោត្រង់ ស្រាប់ម៉ោដល់មានទាហានគេទាក់អាហ្នឹងចូលម៉ោខ្លាងាប់ហ្នឹង!

ដានីៈ ភូមិគេហ្នឹងប៉ុក៏ម៉េច?

ជឿនៈ កន្លែងកូនផ្សារគេតូចហ្នឹងគេហៅខ្លាងាប់!

ដានីៈ គេហៅខ្លាងាប់?

ជឿនៈ បាទ! ដល់ទាមាត់អូរស្រុកក្រោយអញ្ចេះវិញអាហ្នឹងបន្ទាយទីមួយ ដល់ម៉ោអញ្ចេះម៉ោគេហៅបន្ទាយទីពីរ!

ដានីៈ ចុះពូកាលហ្នឹងដូចថាជីវិតកងទ័ពអីយ៉ាងម៉េចដែរ កាលពីសម័យឆ្នាំ៨០ជាង ដូចថារបស់ហូបចុកយើងហូបគ្រប់គ្រាន់ តែកាលហ្នឹងដូចថានៅតាមសមរភូមិដូចថាយើងអាសាវៀតណាមជាមួយកងទ័ពវៀតណាមអី?

ជឿនៈ វៀតណាមវាមានដែរជាមួយកងទ័ពរដ្ឋកម្ពុជា ពី៨១,៨២,៨៣ម៉ោរហូតម៉ោសុទ្ធតែយួន!

ដានីៈ អាសាវៀតណាមដែរប៉ុក៏យូៗវៀតណាមម្ដង?

ជឿនៈ វៀនោះវៀមួយថ្ងៃរាប់មិនអស់ ព្រោះអ្នកដើររកពួកខ្ញុំហើយខ្ញុំជាវៀឆ្នក់ លួចបាញ់អីហ្នឹងមិនទំនេរទេ ។

ដានីៈ យើងធ្វើសង្គ្រាមឈ្លប?

ជឿនៈ បាទ! សង្គ្រាមឈ្លបហ្នឹងគេអត់ទំនេរដែរហ្នឹង ធ្វើរហូតដល់៨៦,៨៧! ព្រោះដើរមិនកើតដល់ពេលអញ្ចឹងឈ្លបលិចឈ្លបកើត!

ដានីៈ ហើយយើងដាក់មីនហ្នឹងដាក់ម៉េចរបៀបដូចថាយុទ្ធសាស្ត្រ យុទ្ធសាស្ត្រយើងធ្វើអីខ្លះដូចថាយើងការពារខ្លួន យើងការពារកុំឲ្យគេចូលម៉ោយើងមានយុទ្ធសាស្ត្រយ៉ាងម៉េចខ្លះទៅ?

ជឿនៈ អាហ្នឹងដូចថាយើងប្រើសង្គ្រាមឈ្លបហ្នឹងធ្វើមិនឲ្យគេដឹងខ្លួនដែរ ហើយមិនថាឡើយតែក្រុមនេះពួកហ្នឹងក៏ហ៊ានចូលទៅធ្វើសកម្មភាពដែរ វាចាំលួចបាញ់ហើយដាក់មីន គ្រាប់កន្ត្រាក់ហើយរត់ម៉ោក្រោយវិញម៉ោ ហើយយួនវាមានផ្លូវវាដើរតែយួនដើរមិនស្ទាត់ដូចខ្មែរយើងទេ!

ដានីៈ យឺតជាងយើង?

ជឿនៈ បាទ! ដើរញ៉ើវញ៉ើវៗ ដល់ពេលអញ្ចឹងយើងទៅលបមើលដឹងផ្លូវត្រៀមអន្ទាក់តែបីនាក់កន្ត្រាក់មីនមួយនាក់បីគ្រាប់ហើយរត់ម៉ោវិញម៉ោ អាហ្នឹងគេថាយុទ្ធសាស្ត្រការពារកម្លាំងអត់ឲ្យគ្រោះថ្នាក់កម្លាំងទេ ឲ្យកម្លាំងខ្លាំងចេះតែអុកឡុកវាណាំដល់ពេលយូទៅវាលំបាកដែរព្រោះវាគ្រោះថ្នាក់រាល់ថ្ងៃ ធ្វើរហូតទាល់តែវារួញលែងហ៊ានដើរក្នុងទីតាំង ដល់ពេលហើយចាប់ផ្ដើមប្រើវិធីផ្សេងទៀតដឹងតែខ្លាំងរួញនៅក្នុងកន្លែងសត្វចូលរន្ធហើយចាប់ផ្ដើមវ៉ៃហ្នឹង!

ដានីៈ ចុះយើងមានធ្វើដូចជារបៀបដែកឆក់ដែកអីហ្នឹង អាហ្នឹងខ្ញុំឮគេនិយាយទេតែមិនដឹងមានអត់ទេ!

ជឿនៈ អាហ្នឹងមានមែន! ដែកឆក់ហ្នឹងធ្វើពីអាសីយើងហ្នឹង ប៉ុន្តែរឿងថ្នាំហ្នឹងគេស្រាវជ្រាវម៉ោពីជើងម៉ោ គេយកពីភូមិឥសាន្តម៉ោអាហ្នឹងបើតាមខ្ញុំឃើញព្រោះខ្ញុំធ្លាប់បានកាន់ជំរុំ ដូចថាយើងក្នុងមួយកងវរៈគេឲ្យ៤០នាក់អញ្ចឹងគេឲ្យម៉ាចំរ៉ូងទេ ហើយប្រដាប់គេដាក់គ្រាងការពារហ្នឹងស្រួលបួលរបស់គេណាស់បំពង់អីអត់ឲ្យប៉ះទេ!

ដានីៈ គេដាក់ម៉េចទៅ?

ជឿនៈ គេយកជ្រលក់ជរវា ដំបូងឃើញគេយកមកស្ងួរពិសោធន៍ គេចាប់សត្វបន្ទុយហើយគេយកជរហ្នឹងមកជ្រលក់ហើយយកបន្ទុយមកឆូតបន្តិចបានគេលែង បើថាបន្ទុយហ្នឹងប៉ះប្រកាច់ត្រលមនុស្សយើងដឹងតែអញ្ចឹងដែរហើយ គេស្ងួរជាថ្នាំជារអី!

ដានីៈ អាហ្នឹងគេដាក់នៅលើដីមែន?

ជឿនៈ គេដាក់នៅលើដី!

ដានីៈ ហើយបើសិនជាមនុស្សដើរទៅជាន់អាហ្នឹង...?

ជឿនៈ បាទ! បើប៉ះទៅវាអត់ចេញឈាមទេវាគ្រាន់តែគ្រោះថ្នាក់ ដល់ពេលយូទៅពួកហ្នឹងខ្លាចអាចំរ៉ូងហ្នឹងដែរព្រោះខាងក្នុងអាចប៉ះគ្រោះថ្នាក់ចំរ៉ូងហ្នឹងច្រើន តែអាក្នុងចំរ៉ូងរាប់ម៉ឺនរាប់សែនហ្នឹងវាមានអាឆក់ហ្នឹងតិចទេ អាហ្នឹងអាចំរ៉ូងឫស្សីយើងធម្មតាហ្នឹងតែវាឈើដែរហ្នឹង មុតហ្នឹងវាខាតដំណើរបើថាមុតកងទ័ពហ្នឹងម៉េចក៏១-២ខែដែរទម្រាំជា ហើយវាបាត់កម្លាំងកាន់តែថយ!

ដានីៈ ចុះហ្នឹងយើងធ្វើអញ្ចឹង ចុះការធ្វើសង្គ្រាមហ្នឹងយើងជួបឧបសគ្គអីខ្លះទៅ?

ជឿនៈ វាមានខ្លះដែរដូចថាកាលនៅព្រៃពួកខ្ញុំមានព្រាបណាស់ ដល់ក្រោយម៉ោក៏រួញមួងណាំចូលឆ្នាំ ៨៦,៨៧,៨៨ហើយអាជិតសមារណកម្ម អាហ្នឹងដូចថាមានគ្រោងការប្រុងវៃព្រោះមានរដ្ឋក្រោះហើយចាប់បានតាំងពីក្រុងប៉ៃលិនម៉ោ គេបែកម៉ោតាមនោះដែរ! គេឲ្យពួកខ្ញុំឡើងជាន់តាមផ្លូវជាតិលេខ៥រុញហ្នុង! ប្រុងវៃហើយដល់ពេលស្ថានការណ៍ប្រែប្រួលទៅក៏ចាប់ផ្សេងទៅ ថាការលំបាកកន្លងម៉ោសង្គ្រាមវាមានការលំបាកដែរ ដូចថាយើងរត់ក្នុងព្រៃហើយយើងវាជួបខ្លះដែរ!

ដានីៈ ជួបម៉េចខ្លះការលំបាក?

ជឿនៈ លំបាកអាពេលថាយើងក្រោយពី៨៤,៨៥ម៉ោពួកគេចាប់វាយមីនតាមព្រំដែនទាំងអស់ ពួកខាងក្នុង!

ដានីៈ អញ្ចឹង?

ជឿនៈ បាទ! ៨៤,៨៥គេរុញពួកខ្ញុំខ្ទាតចេញពីព្រំដែន!

ដានីៈ ចុះពេលគេរុញខ្ទាតចេញពីព្រំដែនហ្នឹងយើងទៅនៅណាទៅ?

ជឿនៈ នៅក្នុងដីថៃ!

ដានីៈ ទៅនៅក្នុងដីថៃ?

ជឿនៈ បាទ!

ដានីៈ តែពូនៅដីថៃកន្លែងណា?

ជឿនៈ គេហៅខ«៨៥»!

ដានីៈ ខ«៨៥»?

ជឿនៈ បាទ!

ដានីៈ ចុះកងទ័ពយើងទៅនៅណា?

ជឿនៈ នៅកន្លែងហ្នឹងទាំងអស់!

ដានីៈ នៅកន្លែងទាំងអស់គ្នា?

ជឿនៈ បាទ!

ដានីៈ ទៅនៅកន្លែងខ«៨៥»ហ្នឹងយូដែរទេ?

ជឿនៈ យូដែរហ្នឹង! ពី៨៤,៨៥,៨៦បានចូលយើងចូលម៉ោវិញ ដាក់ប្រពន្ធនៅហ្នឹងហើយចេញម៉ោវៃយកព្រំដែនវិញ!

ដានីៈ ចុះយើងយកវិញបាននៅឆ្នាំណា?

ជឿនៈ យកបានកាលឆ្នាំ៨៦! កាលរត់ទ័ពវាទៅពីរសន្ទាត់ពួកខ្ញុំ!

ដានីៈ បាទ!

ជឿនៈ អ្នកនៅក្នុងនោះមួយសន្ទាត់អត់ចេញទេ ហើយអ្នកដែលនៅតាមព្រំដែននេះឲ្យដោះស្រាយ ដល់ពេលយួនោះទ្រាំអត់បានដែរ នោះបែដ្តាច់ផ្លូវលែងកើតខាងព្រំដែនរត់ចេញវិញអស់ដែរ!

ដានីៈ រត់ចេញអស់?

ជឿនៈ បាទ!

ដានីៈ ដល់ពេលចូលម៉ោវិញមានគ្រោះថ្នាក់មានអីទេ?

ជឿនៈ មាន! មានមីនមានអីមួយសារទៀតដែរ!

ដានីៈ មីនហ្នឹងខាងណាអ្នកដាក់?

ជឿនៈ ខាងកងទ័ពវៀតណាមអ្នកដាក់!

ដានីៈ ខាងវៀតណាមអ្នកដាក់?

ជឿនៈ បាទ! វាដាក់មីនស្ទាច់ មីនកណ្តាល ហើយនឹងមីនស្ទាច់ម្យ៉ាងទៀតពណ៌ខ្មៅនោះ!

ដានីៈ ដាក់ម៉្តុំណាខ្លះទៅ?

ជឿនៈ និយាយរួមវាបីជាន់ អាតាមមាត់អូរនោះទទឹងប្រហែលជា៥០ពីអូរព្រំដែន ហើយអាខ្សែទី២ កាត់ហ្នឹងដល់អាក្រោយនោះមួយខ្សែទៀត! អានោះគេហៅថាមីនខ្សែទាក់!

ដានីៈ អ៊ំ!

ជឿនៈ ហើយអាពីជាន់នេះអាមុខស្ទាច់អាក្រោយក្តា ក្តាគេបួនជ្រុងតែដ្ឋាកស៊ិចនៅក្នុង!

ដានីៈ អាក្តាហ្នឹងបើជាន់ទៅរលាត់ជើងហ្នឹងមែន?

ជឿនៈ អាក្តាគ្រាន់អស់មួយចំហៀង បើអាស្ទាច់វិញអស់ទាំងពីរហ្នឹង នៅព្រំដែនបើទៅទាំង២ហ្នឹង ហើយគ្រោះថ្នាក់ច្រើនតែស្ទាប់ទៀតណា៎ យើងជាន់ៗមួយចំហៀងទេតែដល់ពេលដាច់ៗទាំងពីរ ខ្លាំងណាស់ ។

ដានីៈ មានគ្រោះថ្នាក់ច្រើនដែរពូ?

ជឿនៈ ច្រើន ហើយច្រើនតែមីនហ្នឹងដែរហ្នឹង សូម្បីតែយើងចូលម៉ោនៅវិញក៏នៅតែមានដែរបន្ត បន្ទាប់ដែរ អាហ្នឹងពេលប្រជាជនម៉ោនៅហើយហ្នឹង!

ដានីៈ ប្រជាជនម៉ោនៅឆ្នាំណា?

ជឿនៈ ប្រជាជនម៉ោនៅឆ្នាម៨៨,៨៩ហើយ!

ដានីៈ ចុះពូមីនហ្នឹងគេដោះអស់នៅ?

ជឿនៈ គេដោះអស់ហើយ!

ដានីៈ ឥលូវអត់ដែលឮសួរមានគ្រោះថ្នាក់ដោយសារមីនអីទេ?

ជឿនៈ អត់ទេ!

ដានីៈ ចុះដូចថាពេលដែលយើងចូលម៉ោនៅវិញឆ្នាំ ដូចថាចូលម៉ោនៅក្រោយពេលដែលយើងចូលម៉ោនៅ១៩៨៩ហ្នឹងមានស្ថានភាពយ៉ាងម៉េច យើងនៅវិគ្នាដដែលឬក៏យ៉ាងម៉េច?

ជឿនៈ វិទៅក្នុងៗនោះវិញទៅតាមដងស្ទឹង!

ដានីៈ បាទ!

ជឿនៈ ចូលទៅជ្រៅណាស់ ហើយមានថ្ងៃណាខ្លះចូលទៅវិនៅស្ពានទឹកថ្លានោះ!

ដានីៈ ស្ពានទឹកថ្លានៅណាទៅ?

ជឿនៈ នៅជិតស្វាយនោះ កន្លែងមហាវិទ្យាល័យនោះ!

ដានីៈ អញ្ចឹងពេលហ្នឹងដូចថាជីវភាពរស់នៅអីយើងមានការហូបចុកគ្រាប់គ្រាន់!

ជឿនៈ បាទ! សំបូរបែបទាំងអាវុធទៀត!

ដានីៈ អាវុធយើងបានពីណាម៉ោ?

ជឿនៈ បានម៉ោពី«១៩០០»!

ដានីៈ «១៩០០»?

ជឿនៈ បាទ! ប៉ុន្តែសំភារៈនៅហ្នឹងគេមិនឲ្យយើងទេ!

ដានីៈ គេអត់ឲ្យយើងទេ?

ជឿនៈ បាទ!

ដានីៈ ពីណាគេយក?

ជឿនៈ ថៃ!

ដានីៈ សំភារៈហ្នឹងយើងបានម៉ោពីណា?

ជឿនៈ យើងបានម៉ោពីចិន!

ដានីៈ បានម៉ោពីចិន?

ជឿនៈ បាទ! បើតាមខ្ញុំដឹងកាលហ្នឹងនៅប៉ុន្មានពាន់តោននោះ ដូចចិនគេផលិតគ្រាប់ម៉ាក!

ដានីៈ យើងទុកនៅដីថៃ?

ជឿនៈ បាទ! កាលហ្នឹងរបៀបថាគេជួយដែរណ៎ា គេឲ្យទឹកដីដាក់ឃ្លាំងដាក់អីដល់ពេលគេដឹងថាយើងត្រូវគេក្រឡាស់ឆាច់!

ដានី៖ អញ្ចឹងតាំងពីយើងចូលម៉ោវិញម៉ោខាងកងទ័ពវៀតណាមអីលែងចូលម៉ោទៀតហើយ? អត់មានចូលម៉ោដល់កន្លែងទេ?

ជឿន៖ ពួកខ្ញុំត្រលប់ម៉ោវិញហើយអត់មានម៉ោបានទៀតទេ មានតែនៅខាងនោះស៊ីងណោះ!

ដានី៖ នៅកន្លែងស៊ីង?

ជឿន៖ នៅតាមតំបន់ព្រៃៗ!

ដានី៖ ពូដឹងពីព្រឹត្តិការណ៍សមារណកម្មដែរអត់ កាលហ្នឹងមូលហេតុអីបានជាយើងធ្វើសមារណកម្ម?

ជឿន៖ ដឹងដែរហ្នឹងកាលហ្នឹង ព្រោះខ្ញុំអត់មានបានរៀនប៉ុន្តែខ្ញុំមានការងារគួសមហ្នឹងគេដែរហ្នឹងផ្នែកវរៈហ្នឹងគេដែរ!

ដានី៖ បាទ!

ជឿន៖ យើងទៅរៀនខាងលើគេលើកថាដល់ពេលដល់វេលាហើយដូច្នេះយើងត្រូវដោះស្រាយដោយសន្តិវិធីព្រោះយើងមិនឈ្នះមិនចាញ់ ដល់យើងចចារនិយាយពីបញ្ហាដូចសម្តេចហ៊ុន សែនគាត់ច្រើននិយាយថានយោបាយឈ្នះ និយាយអារឿងហ្នឹងដែរតើដោះស្រាយបញ្ហាហ្នឹងយ៉ាងម៉េច ដល់ពេលហើយយើងនិយាយអញ្ចេះ ដំបូងយើងនិយាយខាងនោះប៉ុន្តែអ៊ឹគាត់ហៅយើងទៅប្រជុំប្រាប់ថាយើងដល់ពេលដល់វេលាបញ្ចប់សង្គ្រាមហើយព្រោះយើងមិនអាចយកឈ្នះខាងណាៗបានទេ បើយើងធ្វើតទៅទៀតគេជយហើយ កងទ័ពវៀតណាមគេទៅស្រុកគេហើយនៅតែយើងខ្មែរដូចគ្នាទេបើយើងច្បាំងវាមិនឈ្នះវាមិនចាញ់តែទីបញ្ចប់វាងាប់ខ្មែរយើង ដូច្នេះក្មួយៗត្រូវបញ្ចប់ ខ្ញុំក៏ស្ដយោបល់គាត់ថាយើងត្រូវបញ្ចប់បញ្ហាដោយរបៀបណាបើគេមិនឲ្យយើងជួបផង ដល់ហើយគេថាអត់ទេនិយាយគ្នាដោយរលកធាតុអាកាស និយាយចុះឡើងៗដល់ហើយក៏ជួបគ្នាក៏ត្រូវគ្នាទៅ!

ដានី៖ កាលពូទៅប្រជុំជាមួយអ៊ឹៗពូទៅប្រជុំនៅឯណាដែរ?

ជឿន៖ ប្រជុំនៅកន្លែងតាកនហ្នឹង!

ដានី៖ កន្លែងតាកន?

ជឿន៖ បាទ!

ដានី៖ កាលហ្នឹងអ៊ឹណាខ្លះម៉ោប្រជុំ?

ជឿន៖ មានតាសុន សេន មួយដែលគាត់មានតួនាទីជាអគ្គបញ្ជាការ!

ដានី៖ ចុះអៀង សារី?

ជឿនៈ ដល់ក្រោយម៉ោពួកខ្ញុំទៅធ្វើការជាមួយតាអៀង សារីបានដឹងថាវកេបាក់បែកផ្ទៃក្នុងដែរ! ប៉ុន្តែកាលនៅសង្គ្រាមដូចពួកខ្ញុំអីអត់ទាន់ដឹងទេដល់ក្រោយម៉ោអាជិតសមារណកម្មហើយទើបខ្ញុំដឹងថាអីអត់ត្រូវគ្នា គេចេះតែចោទគ្នាទៅវិញទៅម៉ោហើយមិនដឹងម៉េចទៀតយើងមិនអាចដឹងបានទេមួយថាតាសុន សេនក្សត់ប៉ុល ពត ចង់បំបែករដ្ឋចូលទៅជាមួយហ៊ុន សែន ដល់ពេលសុនសេន ថាអៀង សារីនេះចង់ដកពួកខ្ញុំពីកងពល៤៥០នេះកងពលប៉ៃលិននោះថាចង់ចូលជាមួយហ៊ុន សែន ដល់ពេលនេះតាអៀង សារីចូលម៉ោធ្វើការនៅក្នុងហើយគាត់លើកបញ្ហាហ្នឹងដែរតែយើងមិនអាចដឹងថាវៃឈ្នះឬចាញ់ទេទាល់តែយើងទាក់ទងគ្នាទៅចប់ត្រឹមហ្នឹងហើយឲ្យវាអស់ត្រឹមហ្នឹង ហើយក៏គាត់ផ្តាំថាអ្នកណាខ្លាំងយើងអោយអ្នកហ្នឹងទៅកុំអោយអ្នកចាញ់ បើអោយអ្នកចាញ់យើងចប់ហើយ ហើយពួកខ្ញុំក៏ដឹងហើយថាអ្នកណាខ្លាំងនោះអ្នកខ្លាំងនោះមានតែរដ្ឋកម្ពុជាហើយពួកខ្ញុំមានអារម្មណ៍មួយថាមិនបែទៅខាងណាទេសមារណកម្មហើយគឺចូលទៅក្នុងហ្នឹង បើចូលកងទ័ពរដ្ឋកម្ពុជាធានាថាម៉ាចប់ហ្នឹង អ្នកផ្សេងមិនអាចធ្វើអីកើតទេរហូតទាល់សព្វថ្ងៃនេះក៏នៅតែសម្រេចចិត្តអញ្ចឹងដែរឲ្យមេបញ្ជាការមួយលើងទៅស្នងការជាតិ!

ដានីៈ មេបញ្ជាការណាទៅ?

ជឿនៈ ដំបូងគេហៅលោក ប៊ូ សារ៉េត គាត់កងពលដែរហ្នឹង ហើយមានឡាយវ៉ៈម៉ៃ សេងហ៊ានអីហ្នឹងហើយពួកយើងនៅខាងក្រោមនេះរោលដាក់គ្នាម្តង គិតខឹង១ទៅជាខ្មែរក្រហមវិញ កងពលនៅខាងសំពៅលូននេះម៉ោប្រជុំគ្នានៅប្រជុំដែនយើងដែលសព្វថ្ងៃគេហៅថាគីឡូលេខ៩បឹងបេងហ្នឹងប្រឈមមុខគ្នាដាក់គ្នាហ្នឹង បើគេខាងនោះគេថាពួកខ្ញុំខាងម៉ាឡៃនេះហ៊ុន សែន ហើយពួកនេះគេនៅកណ្តាលគេបែមុខពីរគេបែមុខម៉ោខាងនេះផងគេបែមុខទៅខាងប៉ៃលិនផង ព្រោះប៉ៃលិនម៉ោជាមួយពួកខ្ញុំដែរយកអាកាឡាបញ្ចប់សង្គ្រាមហ្នឹងដែរ អាហ្នឹងដូចលោកដឹងហើយដែលលោកខាងលើគេប្រកាសដំបូងគឺអ្នកម៉ាឡៃហ្នឹងហើយជាអ្នកបញ្ចប់!

ដានីៈ បាទ!

ជឿនៈ អញ្ចឹងពួកហ្នឹងត្រូវបែខ្នងទល់គ្នា ប៉ុន្តែពួកខ្ញុំខាងម៉ាឡៃនេះបែមុខទៅខាងប៉ៃលិន ដល់ហើយពួកប៉ៃគេស្រែកសួពួកខ្ញុំថាព្រមបញ្ចប់ឬមិនព្រម ដល់ហើយថាយើងកំពុងតែនិយាយគ្នា ដល់ហើយគេនិយាយច្រើនណាស់គេទៅហើយ ពួកប៉ៃលិនគេម៉ោហ្នឹង ដល់ហើយពួកខ្ញុំដឹងតែអញ្ចឹងអាពួកដែលម៉ោចចារជាមួយហ្នឹងថាមិនកើតទេទាល់តែចូលគ្នាជាមួយពួកម៉ាឡៃម៉ោច្បាំងជាមួយគ្នាឯងទៀតដើម្បីឲ្យវាចប់ហ្នឹងទៅដើម្បីឲ្យសប្បាយ ដល់ហើយគេចូលម៉ោរ៉ាវជួបគ្នាហ្នឹងពួកកងទ័ព! ហើយតាំងពីថ្ងៃហ្នឹងម៉ោក៏វាចប់ទៅ!

ដានី៖ ឆ្នាំណាហ្នឹង?

ជឿន៖ យើងចូលទៅសមារណកម្ម!

ដានី៖ ៩៥ឬ៩៦?

ជឿន៖ ដូចជា៩៦!

ដានី៖ កាល៨៦យើងនៅសង្គ្រាមនៅឡើយ ដល់ពេល៩១យើងមានកិច្ចព្រមព្រៀងជាមួយទីក្រុងប៉ារីស!

ជឿន៖ បាទ!

ដានី៖ កាលអ៊ុន គាត់ចូលម៉ោនៅឆ្នាំ៩៣?

ជឿន៖ បាទ! ខ្ញុំពីមុនខ្ញុំចង់ចាំដែរកត់ត្រាទុកដែរ ដល់ក្រោយម៉ោខ្ញុំក្រវាត់ចោលអស់!

ដានី៖ កាលហ្នឹងយើងចចារតែថ្នាក់កងពលទេ?

ជឿន៖ បាទតែថ្នាក់កងពលទេ ដូចខ្ញុំនេះអីគេមិនសូវឲ្យដឹងទេ!

ដានី៖ អញ្ចឹងដូចថាតាៗអីគាត់អត់មានបាននិយាយគ្នាទៀតទេ?

ជឿន៖ គាត់ម៉ោធ្វើការតែមួយដងហ្នឹងគាត់ឈ្មោះគ្នាហ្នឹងគាត់លែងចេញម៉ោបែកចែកផ្លូវគ្នាហ្នឹងទៅរហូតបាត់អស់រលីង ហើយតាអៀង សារីក៏លែងអត់ឃើញដែរ!

ដានី៖ គាត់លែងម៉ោហើយ?

ជឿន៖ បាទ! ហើយចេះតែសួគ្នាថាអីដូចលែងឃើញម៉ោម៉ាខ្លៃ ដល់ពេលបានឃើញនៅពេលសមារណកម្មទៅឃើញអ៊ំខៀវ សំផនវិញ!

ដានី៖ គាត់ទៅណា?

ជឿន៖ គាត់ម៉ោសួសុខទុកកងពលនៅម៉ាខ្លៃហ្នឹង!

ដានី៖ ចុះអ៊ំខៀវ សំផន កាលហ្នឹងគាត់នៅហ្នឹងដែរ?

ជឿន៖ គាត់នៅខាងជើងនោះ ដល់ហើយអាញ៉ៅអាញ៉ៅម៉េចទេព្វថាខៀវ សំផន គេសមារណកម្មអស់ហើយគាត់មិនមែនបានចូលម៉ោតាមច្រកស្រួលបួលទេ ដូចហ៊ុន សែនក៏មិនដឹងចូលតាមច្រកណាដែរខ្ញុំមិនសូវដឹងរឿងទេ!

ដានី៖ បាទ!

ជឿន៖ យកទៅក្នុងហើយបានបញ្ចេញទៅប៉ៃលិនវិញ!

ដានី៖ បាទ!

ជឿន៖ ហើយខ្ញុំនឹកឃើញថានយោបាយអាច់កំបាំងរបស់ខាងលើជាមួយខាងក្នុងយើងមិនអាចដឹងអស់ទេ ដឹងតែប្រវត្តពីដើមហ៊ុន សែនគាត់ធ្លាប់ជាខ្មែរក្រហមដូចតែខ្ញុំដែរ កាលហ្នឹងគាត់អាយុស្មើគ្នា!

ដានី៖ អាយុស្មើពូដែរ?

ជឿន៖ តែគាត់នៅកង៣៩ កាលហ្នឹងគាត់អត់ទាន់ពិការភ្នែកផង តែបើពិការភ្នែកពិការសម័យសង្គ្រាមជាមួយលន់ នល់ហ្នឹងឯង ហើយនារីដែលថែគាត់ហ្នឹងក៏នៅយើងនេះដែរ ចាស់ហើយឥលូវឈ្មោះយាយរ៉ែមៗ!

ដានី៖ អញ្ចឹង?

ជឿន៖ ដែលហ៊ុន សែន ពិការភ្នែកហ្នឹង!

ដានី៖ គាត់នៅមើលថែ?

ជឿន៖ បាទ! តែគាត់ដឹងគាត់ស្រាវជ្រាវដឹងគាត់ឲ្យលុយចាយដែរហ្នឹង ហ្នឹងអ្នកដែលថែសម្តេចហ៊ុនសែនហ្នឹង តែដល់ពេលដែលខ្ញុំបាត់ដំណឹងអាហ្នឹងគិតទៅដំឡើងការតស៊ូសម័យ៣ឆ្នាំ ខ្ញុំមិនសូវដឹងដែរ ដល់ពីសម័យសង្គ្រាមមុនខ្ញុំដឹងថាគាត់នៅកង៣៩ ហើយហេង សំរិនហ្នឹងជាអគ្គបញ្ជាការរួមពួកខ្ញុំអីដែរហ្នឹង គិតតែខាងកងពលគេហៅកងពល៣៩ខ្លាំងណាស់សម័យមុននោះ!

ដានី៖ ពូអញ្ចឹងដល់ពេលនោះទាហានយើងចចារនូវ ដែលខ្មែរយើងផ្សះផ្សាទៅខ្មែរយើងទាំងអស់គ្នាហ្នឹងលែងមានអីហើយ?

ជឿន៖ បាទលែងមានអីហើយ!

ដានី៖ យើងសមារណកម្មហ្នង?

ជឿន៖ បាទ!

ដានី៖ កងពលគាត់ចូលទៅខាងណាវិញ ពេលយើងចូលជាមួយកងពលរដ្ឋកម្ពុជា?

ជឿន៖ ដំបូងគេស្តុបនៅតាមកងពលចាស់ដដែលៗ ដល់ពេលនេះគេឲ្យចូលទៅពួកខ្ញុំខាង៤៥០នោះទៅចូលខាង៥១សព្វថ្ងៃនេះនៅព្រះនេត្រព្រះ!

ដានី៖ នៅព្រះនេត្រព្រះ?

ជឿន៖ បាទ!

ដានី៖ ចុះតាភាព?

ជឿនៈ តាភាពសព្វថ្ងៃគាត់ឡើងហួសពី៩១ទៅហើយ គេហៅទទួលភូមិភាគ៥ ហើយនៅព្រំដែនហ្នឹងគាត់មានតួនាទីហើយគាត់មានទីតាំងនៅស្វាយក៏មាន នៅបាត់ដំបងក៏មាន ហើយសព្វថ្ងៃមានការងារនៅទទួលភូមិភាគ៥ ។

ដានីៈ ចុះតាផុន?

ជឿនៈ បើតាផុនសព្វថ្ងៃក៏មានការងារនៅភូមិភាគ៥ដែរ តែមិនដឹងថាគាត់អាត្រែតប៉ុន្មានទៅទេ!

ដានីៈ តាផុនចាស់ជាងតាភាព?

ជឿនៈ ចាស់ជាង! តាភាពស្រុកខ្ញុំដែរហ្នឹង!

ដានីៈ អញ្ចឹងក្មេងដែរ?

ជឿនៈ បាទ! ប៉ុន្តែគេក្មេងគេសក់សជាងខ្ញុំ តែគេស្រួលជាងគេស្រណុកជាង!

ដានីៈ ចុះខាងតាកន?

ជឿនៈ តាកនតាំងពីសមារណកម្មម៉ោអត់សូវដែលដឹងរឿងគាត់ដែរហ្នឹង! ហើយខ្ញុំស្គាល់តាកននៅសម័យបីឆ្នាំគាត់ធ្វើការនៅក្រសួងការបរទេសដូចគ្នា ហើយគាត់ធ្វើនៅខាងបញ្ញាការដល់ក្រោយម៉ោមិនសូវបានជួបគ្នាដែរខ្ញុំនៅព្រំដែនសំពៅលូនហ្នឹងក៏អត់សូវបានជួបគ្នាដែរ!

ដានីៈ ចុះតាហុងគាត់នៅណា?

ជឿនៈ តាហុងសព្វថ្ងៃនៅផ្ទះ!

ដានីៈ នៅភូមិណា?

ជឿនៈ នៅភូមិថ្មី! ដូចម៉ោពីនោះខាងឆ្វេងដៃមានផ្ទះមួយរៀបឥដ្ឋក្រហមច្រូងប្រាងហ្នឹង ផ្ទះតាហុងជាប់ៗហ្នឹងផ្ទះរាងស្រួចផ្ទះបុរាណ គាត់នៅម្នាក់ឯងហ្នឹង!

ដានីៈ អ៎នៅម្នាក់ឯងទេ?

ជឿនៈ បាទ!

ដានីៈ ចុះគាត់អត់មានធ្វើការអីទេ?

ជឿនៈ មិនដឹងគាត់ធ្វើការអីខ្ញុំមិនសូវដឹងដែរហ្នឹង គាត់ដូចថាខាងសម្របសម្រួលអីរឿងគណៈបក្សអីខ្ញុំមិនសូវដឹងដែរ គាត់អាសាផ្តាំខ្ញុំឲ្យទៅលេងដែរហ្នឹង!

ដានីៈ អ៎គាត់មានផ្តាំពូឲ្យទៅលេងដែរ?

ជឿនៈ បាទ!

ដានីៈ ស្គាល់ពូច្បាស់ដែរ?

ជឿនៈ ស្គាល់ច្បាស់ដែរព្រោះខ្ញុំធ្លាប់នៅជាមួយគាត់តាំងសម័យបីឆ្នាំនោះ!

ដានី៖ ចុះពូពេលយើងសមាហរណកម្មហើយយ៉ាងម៉េចទៀតទៅពូ ម៉េចទៅយើងផ្លាស់ប្តូរជីវភាពកងទ័ពប្តុកឹងដែល?

ជឿន៖ ខ្ញុំតាំងពីពេលហើយម៉ោខ្ញុំនៅតែកងទ័ពដដែលមិនទាន់កាត់ផង!

ដានី៖ ពូធ្វើកងទ័ពនៅណា?

ជឿន៖ នៅ៩១! ដល់ក្រោយម៉ោគេថាខ្ញុំដល់អាយុកាត់ហើយ ដល់ហើយគេទម្លាក់ម៉ោខេត្តរហូតដល់សព្វថ្ងៃហ្នឹងអត់មានកាត់ទេ!

ដានី៖ ឥលូវឈ្មោះពូនៅសឹករងខេត្តដដែល?

ជឿន៖ នៅសឹករងខេត្តតែមានឈ្មោះត្រៀម កាលទៅបើកលុយគេថាកាត់ខែ១០នេះឯង ហើយគេឲ្យលេខទូរស័ព្ទម៉ោថាបើមិនថ្ងៃ១៥ចុងខែគេអត់ឲ្យដើរទៅណាទេ ខ្លាចគេប្រកាសយកទៅ!

ដានី៖ គេប្រកាសយ៉ាងម៉េច គេឲ្យលុយយើង?

ជឿន៖ គេឲ្យលុយតែគេទម្លាក់ឈ្មោះយើងម៉ោសង្គមកិច្ច ព្រោះគេថាខ្ញុំយើងហ្នឹងទាហានអាត្រែតណាំទៅបើកប្រាក់ខែរដ្ឋ មិនដឹងគេកាត់ពេលណា ហើយគេទម្លាក់ម៉ោស្រុកហ្នឹងគេឲ្យលុយក៏វិតណាៗ តែបើតាមខ្ញុំមើលឯកសារសម្រាប់តែអ្នកអត់មានដី តែខ្ញុំមានដីយើងមិនអាចបានទេ កាលហ្នឹងខ្ញុំបដិសេធថាខ្ញុំបើថាឲ្យដីសម្បទានដូចថាដីនៅចំណុចដែរថាថៃគេចង់វៃចង់កាត់ខ្ញុំទៅនៅបានតែលុយត្រូវបើកឲ្យខ្ញុំព្រោះខ្ញុំត្រូវការលុយជាងដី ព្រោះចាស់ហើយបានលុយហ្នឹងម៉េចណាស់ក៏ខ្ញុំបានទៅមើលប្រាសាទ បានទៅមើលកំពង់សោមសប្បាយចិត្តបន្តិចដែរ គេឯកភាពដែរតែមិនដឹងម៉េចដល់ពេលទៅបើកលុយកាលខែ៩ខែភ្ជុំហ្នឹង បើកមុនភ្ជុំមួយថ្ងៃពីរ!

ដានី៖ បើកបានមួយខែប៉ុន្មានដែរ?

ជឿន៖ មួយខែ៣០ម៉ឺនជាង!

ដានី៖ ចុះក្រៅពីធ្វើទាហានពូមានប្រកបមុខរបរអីផ្សេងទៀតទេ?

ជឿន៖ ធ្វើចំការស្រែ!

ដានី៖ ធ្វើចំការស្រែ?

ជឿន៖ បាទ!

ដានី៖ ពូមានដីច្រើនដែរ?

ជឿន៖ ដីអត់ច្រើនប៉ុន្មានទេ ប្រហែល៦ហិចតាអីហ្នឹង!

ដានី៖ ចុះដូចការធ្វើស្រែយើងយ៉ាងម៉េចដែរបានគ្រប់គ្រាន់អត់?

ជឿន៖ គ្រប់គ្រាន់ដែរស្រូវអត់មានខ្វះទេ ហូបមិនអស់ផង!

ដានី: ស្រូវធ្វើបានយើងហូបអត់អស់ទេ?

ជឿន: បាទ! យើងធ្វើចំការខ្លះអីខ្លះទៅវាគ្រាន់ហ្នឹងទប់ទល់ម៉ារស់បាន ឲ្យមានដូចគេវាមិនមានទេ!

ដានី: ពូប្រៀបធៀបមើលថាជីវភាពឥលូវហើយនឹងជីវភាពសមារណកម្មហើយពីមុនហ្នឹងការរស់នៅរបស់ពូកាខុសប្លែកគ្នាយ៉ាងម៉េចដែរ?

ជឿន: វាខុសប្លែកថាបើគិតទៅវាអត់មានសាច់ជ្រូកសាច់គោហូបដូចរាល់ថ្ងៃទេ រាល់ថ្ងៃហ្នឹងយើងចង់ហូបអីក៏បាន ដូចកាលនោះយើងមានបាយហូបមែនតែម្ហូបយើងរកខ្លួនឯង ឥលូវក៏យើងដូចតែរកខ្លួនយើងដែរតែយើងរកតាមផ្សារវាងាយជាងរកតាមបឹង បើគិតពីសម័យនោះម៉ោសម័យនេះវាខុសគ្នា សម័យនេះវាស្រួលមហាស្រួល!

ដានី: សម័យនេះស្រួល?

ជឿន: បាទ!

ដានី: ពូគិតថាសម័យនេះស្រួលជាង?

ជឿន: ស្រួលជាងសង្គមយើងមុនឆ្ងាយណាស់ ព្រោះយើងមានឱកាសធ្វើអីទាំងអស់!

ដានី: កាលពីសម័យយើងតស៊ូយើងមានរបបអីដែរតែយើងលំបាក?

ជឿន: បាទដូចថាយើងចង់បានម្ហូបទាល់តែយើងទៅរកនៅបឹង!

ដានី: បាទ!

ជឿន: ហើយអ្នកអត់ចេះរកនៅតែអត់ដដែលហ្នឹង យ៉ាប់ដែរហ្នឹង ហើយរាល់ថ្ងៃនេះយើងអត់លំបាកទេសូម្បីតែអ្នកអត់រកការងាររស៊ីឈ្នួលគេក៏នៅតែស្រួលដែរ យកលុយហ្នឹងទៅទិញម្ហូបវាងាយ!

ដានី: អញ្ចឹងពូគិតថាឥលូវវាស្រួលជាងពីមុន?

ជឿន: បាទ! ស្រួលទាំងការរក ស្រួលទាំងការរស់នៅ បើយើងគិតក្មេងរៀនក៏បានតាមចិត្តហើយយើងតាំងពីសម័យតស៊ូម៉ោមិនដែលមានសាលារៀនទេ ខុសគ្នាណាស់ ហើយមិនដែលឮពាក្យថានិស្សិតអីផង សម័យខ្ញុំនេះបើតាមខ្ញុំគិតទៅតាំងពីខ្ញុំអាយុ២០ម៉ោពាក្យនិស្សិតហ្នឹងចប់បាត់ដល់ឥលូវកូនខ្លួនឯង អញ្ចឹងបានសព្វថ្ងៃនេះខ្ញុំមានកូនជានិស្សិតមួយដែរហ្នឹង!

ដានី: រៀននៅណា?

ជឿន: រៀននៅបឹងត្របែកភ្នំពេញ?

ដានី: អ៎!រៀននៅបឹងត្របែក?

ជឿន: បាទ! មិនដឹងគេចង់រៀនស្អីទេ ប៉ុន្តែកាលពីមុនគេចំនួលខាងហិរញ្ញអីណាគេ!

ដានី: ខាងសេដ្ឋកិច្ច?

ជឿនៈ បាទខាងសេដ្ឋកិច្ច! គេខ្លាំងខាងហ្នឹង!

ដានីៈ ឥលូវបានឆ្នាំទី២ហើយ?

ជឿនៈ បាទ!

ដានីៈ ចុះពូមានធ្លាប់និយាយពីរឿងរ៉ាវជីវិតដូចថាការតស៊ូអីនិយាយប្រាប់កូនទេ!

ជឿនៈ កូនដឹង!

ដានីៈ ពូដែលនិយាយប្រាប់ទេ?

ជឿនៈ និយាយដែរហ្នឹង!

ដានីៈ និយាយប្រាប់ដែរ?

ជឿនៈ និយាយអារឿងយើងឆ្លងកាត់ពីដំណាក់កាលមួយទៅដំណាក់កាលមួយ សូម្បីតែកូនខ្ញុំមីបងត្រឹមដឹងពាក្យថាសង្គ្រាមខ្លះដល់ពេលក្រោយពួកប្អូនវាមិនសូវបានចាំច្បាស់ផង វាកើតអាសមារណកម្មហ្នឹង សមារណកម្មហ្នឹងបានប៉ុន្មានឆ្នាំយើងសំបូរទៅដោយទូរទស្សន៍ ស៊ីឌី បាស់ និយាយរួមចាប់តាំងពីសមារណកម្មម៉ោ ពីដើមយើងនិយាយថាមានអ្នកសប្បាយតែពីក្នុងណាំ មានកន្លែងចាក់បាស់ចាក់អីរាំ ដល់ពេលសមារណកម្មពិប កាលហ្នឹងសម្តេចហ៊ុន សែន គាត់ម៉ោមានតាំងពីអាឡូ មានតាំងពីសេះហោះម៉ោដាក់នៅយើងវាលសាលារៀននេះ ហើយអ្នកម៉ោពីក្នុងរ៉ាអីហ្នឹងល្បីៗម៉ោលេងចុះឡើងហ្នឹង ពីមុនមានលេងគិតលុយណាលេងហ្វ្រីស្រាប់ពួកហ្នឹងគេជយអស់បានពួកនេះគេចាប់ផ្តើមបង្កើតដោយខ្លួនឯង ព្រោះមិនយូទេតំបន់ព្រំដែននោះដូចថាលុយគេមានគេនៅលាក់ គេថាអត់មានអាកាសដល់ពេលសមារណកម្មហើយអាកាសវាម៉ោមិនបានប៉ុន្មានឆ្នាំផងមានបាស់មានអីសព្វគ្រប់ផ្ទះ ដល់ពេលដល់សព្វថ្ងៃនេះមានភ្លើង២៤ម៉ោងអត់រលត់ទៀតលែងស្ងាត់ហ្នង មួយរយៈនេះស្ងាត់ដោយមានភ្ញៀវទេ ភ្ញៀវផ្ទះណាក៏ថ្លង់ដែរចាក់បាស់ពេញទឹកពេញដី អញ្ចឹងបានថាសម័យឥលូវវាសប្បាយវាស្រួលវាណាស់ ។

ដានីៈ ពូទៅលេងស្រុកបានប៉ុន្មានដងដែរ?

ជឿនៈ ខ្ញុំទៅបានបីដងហើយ!

ដានីៈ ទៅកាលណាខ្លះ?

ជឿនៈ មិនចាំទេ!

ដានីៈ បែកផ្ទះយូមែនបានទៅលេងផ្ទះ?

ជឿនៈ កាលសមារណកម្មបីឆ្នាំហើយបានយើងបានទៅ!

ដានីៈ អ៎សមារណកម្មបីឆ្នាំហើយបានពូបានទៅលេងផ្ទះ?

ជឿនៈ បាទទៅអើតស្រុកមួយភ្លែត!

ដានីៈ អញ្ចឹងពូចេញពីផ្ទះតាំងពីឆ្នាំណា?

ជឿនៈ តាំងពីឆ្នាំ៧៣!

ដានីៈ តាំងពីឆ្នាំ៧៣?

ជឿនៈ បាទតាំងពីថ្ងៃទី១ ខែ១ ឆ្នាំ១៩៧៣មោះរហូតយើងសមារណកម្មបីឆ្នាំក្រោយបានយើងបានទៅស្រុកហ្នឹង!

ដានីៈ ទៅបានយូទេពូ?

ជឿនៈ ទៅបានយូដែរ! ព្រោះអាសម័យដែលចប់មួយសារហើយហ្នឹងវាមានបងប្អូនខ្ញុំមិនឲ្យទៅ ព្រោះខ្ញុំនៅភ្នំពេញហ្នឹងវាជិតហើយតែគេមិនឲ្យទៅស្រុក បង១ខ្ញុំអីដឹងរឿងនៅខាងក្រោយថាគេច្របូកច្របល់!

ដានីៈ អ៊ំបងប្អូនរបស់ពូគាត់ប្រាប់ថាកុំឲ្យទៅលេងស្រុក?

ជឿនៈ កាលនោះគាត់ធ្វើទ័ពហើយគាត់អាសាចេញចូល ខ្ញុំសម័យនោះខ្ញុំផ្លាស់ពីកងទ័ពម៉ោចូលក្រសួងការបរទេសនេះ យើងធ្វើការផ្នែកស៊ីវិលផ្នែកនយោបាយនោះគាត់ហាមអត់ឲ្យទៅទេ!

ដានីៈ ហេតុអីបានជាគាត់ហាមពូមិនឲ្យទៅ?

ជឿនៈ គាត់ថានៅខាងក្រោយនោះវាមានគេដូចថាកងឈ្លប កងមហាជនអីហ្នឹង តែឃើញយើងទៅលេងគេកោតសរសើរយើង អ្នកថ្មីទៅពីណាប្ដូក៏ទៅការអី បើដឹងរឿងម៉ែឪដូចថាហូបបបរហូបដំឡូងអីទៅ ហើយអាហ្នឹងបើតាមខ្ញុំយល់ចិត្តបងខ្ញុំគាត់ស្មានខ្លាចខ្ញុំហ្នឹងមានអារម្មណ៍នេវនាវ ម៉ែឪលំបាកនោះហើយយើងខ្ញុំទៅតស៊ូលំបាកនោះដ៏អញ្ចឹងអ្នកនៅក្រោយលំបាកណាំ ហូបមិនគ្រប់គ្រាន់ខ្លាចយើងហ្នឹងខឹងនេវនាវពួកឈ្លបហ្នឹងគេចាប់យើងយកទៅវៃបាញ់ចោល ដល់ពេលអញ្ចឹងខ្ញុំដេកគិតទៅបងខ្ញុំគាត់និយាយមយ៉ាងដែរ ដល់ពេលអញ្ចឹងយើងចេះតែទ្រាំ១ទៅរហូតដល់យើង៧៩មួយសាទៀតវាវិតតែច្រើនឆ្នាំហ្នង ទម្រាំតែចប់មួយសាទៀតបានទៅស្រុក ។

ដានីៈ ចុះពូពេលដែលពូទៅស្រុកដំបូងពូមានអារម្មណ៍យ៉ាងម៉េចដែរដូចថាយើងបែកគ្នាយូ ពេលទៅដំបូងមានអារម្មណ៍ខុសប្លែកយ៉ាងម៉េចទៅ ដូចថាកាលយើងមិនទាន់ចេញពីផ្ទះយើងនៅជាមួយឪពុកម្ដាយបងប្អូនអ្នកជិតខាងអីដូចថាយើងស្និទស្នាលជាមួយគ្នា ហើយយើងចេញពីផ្ទះយូជាង ២០ឆ្នាំហើយ ហើយដល់ពេលសមារណកម្មបីឆ្នាំហើយបានទៅលើកទីមួយដែលយើងទៅឃើញផ្ទះពេលហ្នឹងមានអារម្មណ៍យ៉ាងម៉េចទៅ?

ជឿនៈ បើគិតទៅកាលនោះខ្ញុំនិយាយមិនកើតដែរហ្នឹង ព្រោះបងប្អូនញាតិមិត្តមាមីងមួយគាត់ឃើញគាត់យំគ្រប់គ្នា ហើយគេថាស្មានតែខ្ញុំហ្នឹងស្លាប់បាត់ហើយ! ហើយមាមីងអីថាធ្វើបុណ្យឲ្យហើយដល់ពេលឃើញមុខមានអីគិតតែពីយំ ហើយបងប្អូនទាំងក្មួយទាំងមាមីងម៉ោអោបរិតទាំងអស់គ្នា ដល់ពេលអស់ពីយំទៅនាំគ្នាសប្បាយទៅផ្ទះណាក៏គេជប់លៀង ។

ដានីៈ ពូទៅលេងបានប៉ុន្មានថ្ងៃដែរ?

ជឿនៈ ទៅបានមួយអាទិត្យបានម៉ោវិញ!

ដានីៈ ចុះដូចថាមិត្តកាលពីក្មេងអីពូមានបានជួបទេ?

ជឿនៈ ជួបច្រើនដែរ?

ដានីៈ ម៉េចទៅមុនដំបូង?

ជឿនៈ ជួបទៅមានអីទេគ្រាន់តែសួរសុខទុក្ខគ្នា ដេរគ្នាលេងតែប៉ុណ្ណឹងឯង ចុះឡើងៗគេថាឯងស្លាប់ដល់ពេលអត់ឃើញយើងស្លាប់គេថាអាយុវែងម្ល៉េះ ហើយគេផ្តាំឲ្យទៅលេងនោះ ។

ដានីៈ ប៉ុន្តែបើតាមអារម្មណ៍របស់ពូផ្ទាល់ដូចថាពូធ្លាប់ចេញពីផ្ទះយូ អារម្មណ៍របស់ពូគិតថានេះជាផ្ទះសម្បែងជាស្រុកកំណើតពូតើពូចង់នៅនេះជាងឬពូចង់ទៅនៅនោះ?

ជឿនៈ អត់ទេសព្វថ្ងៃអារម្មណ៍នៅនេះច្រើនជាង ទៅនោះវាមិនមែនជារបស់គេអាករអីរបស់យើងទេ សព្វថ្ងៃខ្ញុំចេញម៉ោវាមានទឹកដីឲ្យមួយកន្លែងតែខ្ញុំទៅខ្ញុំថាខ្ញុំមិនយកទេ ម្យ៉ាងខ្ញុំទុកឲ្យប្អូនខ្ញុំ ព្រោះវាអត់មានអារម្មណ៍ថាដីហ្នឹងជាដីគេជូនតាអីអត់ទេ គំនិតរបស់ខ្ញុំអញ្ចឹងថាវាគ្មានអីអស្ចារ្យទេ អ្នកដែលនៅស្រុកកំណើតមិនបានដឹងថាទឹកដីខ្លួនឯងប៉ុណ្ណាទេ ខ្ញុំនិយាយកាលអារម្មណ៍ខ្ញុំនៅក្មេងខ្ញុំចង់តែដើរឲ្យបានដឹងជុំវិញប្រទេស ប៉ុន្តែវាមិនបានដូចបំណងទេ ។

ដានីៈ ដល់ពេលពូទៅលេងស្រុកពូនឹងដល់ខាងនេះវិញទេ?

ជឿនៈ នឹក!

ដានីៈ អញ្ចឹងដល់ពេលទៅនោះពូនឹកនេះវិញ?

ជឿនៈ វានៅតែនឹកនេះ!

ដានីៈ ម៉ោពីយើងផ្សាភ្ជាប់ជីវិតនៅនេះ!

ជឿនៈ សូម្បីតែរាល់ថ្ងៃនេះម៉ោលេងក៏មិនអាចនៅយូបានវាដូចថាអារម្មណ៍នៅចំនាំអីៗអញ្ចឹងណា៎!

ដានីៈ ចុះដូចថាភាពជិតស្និទវាមានការខុសពីកាលយើងនៅក្មេងឬក៏យ៉ាងម៉េច?

ជឿនៈ វាខុសពីកាលយើងនៅក្មេង ព្រោះខ្លះគេភ្លេចយើងទៅ យើងដើរគេមិនហៅយើងទៅ ហើយគេមិនដឹងថាយើងជាអ្នកណា យើងដូចថាអ្នកចំនូលថ្មីទៅគេមិនស្គាល់គេមិនអី ក្រៅពីបងប្អូនយើងគេមិនដឹងថាយើងជាអ្នកណាផង!

ដានីៈ បាទ!

ជឿនៈ ព្រោះនឹកឃើញថាខ្លួនឯងបាត់ពីស្រុក១០,២០ឆ្នាំហើយបានទៅមួយដង គេអត់ចាំយើងបានទេ

ដានីៈ ហើយម៉ោនេះពូមានញាតិមិត្តជិតស្និទ?

ជឿនៈ ម៉ោនេះទៅកន្លែងណាក៏គេស្គាល់ដែរ ស្គាល់គ្នាទៅដូចថាការជិតស្និទវាដូចជាបងប្អូនដែរ!

ដានីៈ អ្នកនៅភូមិផងរបងជាមួយពូ?

ជឿនៈ កាលខ្ញុំទៅសំពៅលូន ទៅប៉ៃលិនអី សូម្បីតែកាលនោះពួកខ្ញុំនេះវាតឹងតែងខាងប៉ៃលិនគេមកជួយ អាគេមកជួយ៣,៤ខែហ្នឹងកងទ័ពរាប់រយរាប់ពាន់ម៉ោហ្នឹងស្គាល់គ្នាទៅ ដល់ពេលទៅជួបគេទាញដីទាញជើងទៅផឹកស៊ីសប្បាយទៅ ត្រូវច្រៀង១ ត្រូវរាំ១ជាមួយគ្នាហ្នឹង តែអត់មានប្រុសស្រីអីទេវាមានតែចាស់គ្នាឯងហ្នឹងប្រុសដូចគ្នាហ្នឹង កាលហ្នឹងវាទូលាយជាងយើងទៅស្រុកកំណើត ។

ដានីៈ ដូចថាយើងនៅនេះវាស្គាល់វាស្និទស្នាល ដល់ពេលស្រុកកំណើត?

ជឿនៈ វាយូហើយ! យើងសប្បាយព្រោះថាយើងបានជួបបងប្អូនមីងមាតែដល់ពេលធ្វើបុណ្យធ្វើទានហើយក៏ម៉ោវិញម៉ោ ។

ដានីៈ ចុះលើកទីពីរទៅពេលណា?

ជឿនៈ ពេលនោះបើតាមខ្ញុំដឹងក្រោយម៉ោ២ឆ្នាំទៀតបានទៅទៀត ហើយក្រោយម៉ោអាចចូល៤ឆ្នាំបានទៅម្តងទៀតហូតដល់សព្វថ្ងៃបីឆ្នាំហើយអត់មានបានទៅទៀតទេ កាលមុនថាទៅថ្ងៃភ្ជុំនេះតែឥលូវវារាំងរាអារឿងសណ្តែករឿងអីហ្នឹងអត់ទៀត ។

ដានីៈ ពូទៅហ្នឹងស្នាក់នៅយូដែរ?

ជឿនៈ ទៅមិនយូទេ ទៅប្រហែលមួយអាទិត្យហ្នឹងម៉ោវិញហើយ!

ដានីៈ ទៅម្នាក់ឯងឬក៏ទៅទាំងមីងទាំងអីទាំងអស់គ្នា?

ជឿនៈ ទៅ២ដងបានម៉ែវាទៅជាមួយ មុនដំបូងខ្ញុំទៅម្នាក់ឯងទេដល់ក្រោយម៉ោបានទៅពីរនាក់ម៉ែវា!

ដានីៈ កូនអត់ទៅទេ?

ជឿនៈ កូនទៅមីពៅ!

ដានីៈ ហើយបង១អត់ទៅទេ?

ជឿនៈ អត់ បង១មិនដែលមានមួយណាទៅទេ!

ដានីៈ អត់មានមួយណាទៅស្គាល់ស្រុកកំណើតទេ?

ជឿនៈ អត់! បើទៅ១ខាងម៉ែវា!

ដានីៈ អ៊ំទៅខាងម្ដាយ?

ជឿនៈ បាទ! ទៅខាងតាកែវ ខាងទន្លេបាទី!

ដានីៈ ពូមានធ្លាប់ទៅស្រុកកំណើតខាងមីងទេ?

ជឿនៈ ទៅ១បាន៤ដង លើសខ្ទួនឯង!

ដានីៈ អញ្ចឹង?

ជឿនៈ បាទ ទៅការក្មួយទៅធ្វើបុណ្យ សូម្បីតែគេនាំទៅធ្វើបុណ្យនៅខេត្តកំពង់ស្ពឺក៏ខ្ញុំហួសទៅផ្ទះម៉ែវាដែរ ។

ដានីៈ ចុះពូកាលឆ្នាំ៧៣ពូចូលទៅជិបូងធ្វើកងទ័ព?

ជឿនៈ ចូលទៅជិបូងកងទ័ពរហូត!

ដានីៈ ធ្វើកងទ័ពនៅណាទៅកាលហ្នឹង?

ជឿនៈ នៅខេត្តកំពង់ឆ្នាំង!

ដានីៈ គេហៅកងទ័ពអីគេកាលហ្នឹង?

ជឿនៈ គេហៅកងទ័ពតំបន់! ខ្ញុំកាលនៅនោះគេហៅកងពិសេសទៀត តំបន់កំពង់ឆ្នាំងគេហៅតំបន់៣១ ហើយដាក់លេខកងពិសេសនោះ៣១អញ្ចឹងហ្នង!

ដានីៈ កង៣១ខ្ញុំឮដែរ!

ជឿនៈ វាច្រើនដែរជាមួយកងសាធារណរដ្ឋនោះ!

ដានីៈ វាជាមួយកងទ័ពលន់ នល់?

ជឿនៈ ដូចអាកងពល៨០អីរលាយអស់ដោយសារពួកខ្ញុំ ។

ដានីៈ កាលហ្នឹងមានឋានៈជាអីដែរ?

ជឿនៈ ជាកងពិសេសដែរ?

ដានីៈ កងពិសេសហ្នឹងមិនមែននៅជាមួយកងពលទេ?

ជឿនៈ អត់ទេ!

ដានីៈ នៅជាមួយកងអីគេ?

ជឿនៈ នៅជាមួយវរៈសេនាធំគេ អត់ទាន់ដល់កន្លែងកងពលទេ ព្រោះកាលនោះកងតំបន់៣១ហ្នឹងអត់ទាន់បានមួយកងពលទេបានតែមួយវរៈសេនាធំ!

ដានីៈ មួយវរៈសេនាធំ?

ជឿនៈ កាលហ្នឹងវាមាន៣០១,៣០២, ៣០៣, ៣០៤, ៣០៥, ៣០៦ មាន៦វរៈសេនាតូច កាលហ្នឹង៦វរៈសេនាតូចហ្នឹងពួកខ្ញុំមាន១០គេរៀបជាមួយកងម៉ា៦វរៈហ្នឹងហ្មង!

ដានីៈ កងពិសេសហ្នឹងមែន?

ជឿនៈ បាទ!

ដានីៈ អញ្ចឹងវរៈសេនាតូច?

ជឿនៈ បាទ!

ដានីៈ កងពិសេសហ្នឹងឋានៈស្មើរហ្នឹងអី?

ជឿនៈ ស្មើរនឹងកងវរៈគេដែរហ្នឹង!

ដានីៈ យើងស្តាប់តែ...?

ជឿនៈ ស្តាប់តែមេមួយប៉ុណ្ណោះ បើវរៈតូចនេះយើងមិនអាចស្តាប់ទេ!

ដានីៈ អញ្ចឹងយើងស្តាប់តែស្តាប់វរៈសេនាធំ?

ជឿនៈ ព្រោះវរៈសេនាតូចហ្នឹងបើត្រូវការពួកខ្ញុំទៅវៃ ទាល់តែពួកហ្នឹងទាក់ទងមកខ្ញុំបានខ្ញុំទៅជួយ កាលហ្នឹងមានសិទ្ធគួសមដែរហ្នឹង! ហើយដើរនិយាយរួមបើខ្ញុំចេញមួយនាក់ទៅគេនោះគាត់នោះជាមេដែរទៅជាមួយខ្ញុំ ដូចថាយើងត្រូវការខាងលើគេឲ្យពិនិត្យភូមិសាស្ត្រយើងខ្លាំងប់ ដល់ហើយក៏មានកូនទាហានម៉ោ គេនោះក៏វរៈយើងនេះក៏វរៈ ។

ដានីៈ កាលនោះពូអាយុប៉ុន្មាន?

ជឿនៈ កាលនោះខ្ញុំអាយុ២៣ហើយ កំពុងពេញសាហាវដែរហ្នឹងគ្មានខ្លាចងាប់ទេ បាញ់គ្នាដូចសប្បាយដូចរាំបាស់កាលសម័យហ្នឹង!

ដានីៈ កាលហ្នឹងពូមានបានហាត់អីទេកាលហ្នឹង?

ជឿនៈ ហាត់នៅស្រុកកំពង់លែង៣ខែ ឡើងម៉ោខាងលើម៉ោហាត់ត្រពាំងលួននេះ៣ខែទៀត ហាត់នៅត្រពាំងលួនេះបានយ៉ាប់ព្រោះដីវាក្រៀម!

ដានីៈ កាលហ្នឹងប្រធានវរៈសេនាធំឈ្មោះអីដែរ?

ជឿនៈ ឈ្មោះតា ជីប!

ដានីៈ តាជីប?

ជឿនៈ បាទ! តែក្រោយម៉ោពួថារញ៉េរញ៉ៃហើយខ្ញុំទៅនៅភ្នំពេញពួថាចាប់ម៉េចអស់ហើយទេ សម័យហ្នឹងមិនដឹងគេបោសសម្អាតគាត់យ៉ាងម៉េចខ្ញុំមិនដឹងដែរ!

ដានីៈ ចុះពូម៉េចបានទៅភ្នំពេញ?

ជឿនៈ កាលនោះគ្រាន់តែចប់ភ្លាមគេជ្រើសរើសសមាសភាពធ្វើការងារធ្វើការនៅក្រសួងការបរទេស!

ដានីៈ បាទ!

ជឿនៈ ហើយកាលនោះតាៗគាត់ធ្លាប់ដឹងខ្ញុំ គេថាបញ្ហាការរើក្មេងជាងគេតែមានប្រជាប្រិយព្រោះធ្វើការងារទូតបាន គេនឹកស្មានតែពួកខ្ញុំហ្នឹងមាននិស្ស័យទៅធ្វើទូតបាន ដល់ពេលហើយគេឲ្យខ្ញុំចេញម៉ោ ដល់ពេលម៉ោមានមោទនៈភាពខ្លួនឯងណាស់!

ដានីៈ កាល៧៥?

ជឿនៈ បាទ!

ដានីៈ ប៉ុន្មាននាក់ដែលគេបញ្ជូនម៉ោហ្នឹង?

ជឿនៈ ម៉ោ៣០នាក់!

ដានីៈ កងពិសេសទាំងអស់មែន?

ជឿនៈ ម៉ាកងខ្ញុំហ្នឹងបានតែខ្ញុំមួយទេ! តែកងវរៈសេនាតូច៦វរៈសេនាហ្នឹងគេដកម៉ោគំរប់នឹងខ្ញុំ គេ៦វរៈហ្នឹងគេបាន២៩ហើយខ្ញុំទៅម្នាក់ទៀតបាន៣០ ។

ដានីៈ ទៅដល់ដំបូងទៅនៅណាទៅ?

ជឿនៈ ទៅដល់តដំបូងទៅនៅកន្លែងខ្មែរស្វូវៀត!

ដានីៈ កន្លែងណា?

ជឿនៈ កន្លែងសាលាខ្មែរស្វូវៀត?

ដានីៈ កន្លែងសាលាស្វូវៀត?

ជឿនៈ ជិតពោធិ៍ចិនតុងនោះ ឃើញគេដាក់ខ្មែរស្វូវៀតហ្នឹងកាលនោះ តាខៀវ សំផនគាត់យកធ្វើជាសាលាសម្រាប់អប់រំខ្មែរក្រហមណា៎ ប៉ុន្តែខ្ញុំដឹងតែមានផ្លាកគេពីសង្គមគេដាក់ខ្មែរស្វូវៀតហ្នឹងប៉ុន្មានដាន់ទេកាលហ្នឹង ដូចជា៣ឬ៤ទេកាលហ្នឹង ទៅនៅរៀនហ្នឹងបានច្រើនខែដែរបានចេញទៅធ្វើការងារ ។

ដានីៈ ទៅរៀនហ្នឹងបានច្រើនខែដែរ?

ជឿនៈ បាទ!

ដានីៈ តាខៀវ សំផនគាត់អ្នកគ្រប់គ្រង?

ជឿនៈ បាទ!

ដានីៈ ហើយដល់ពេលរៀនចប់ហ្នឹងទៅធ្វើអីគេ?

ជឿនៈ គេបែកគ្នា គេឲ្យខ្ញុំម៉ោកន្លែងតាអៀង សារីខាងក្រសួងការបរទេស ។

ដានីៈ ចុះអ្នកផ្សេងៗទៀត?

ជឿនៈ ម៉ោជាមួយខ្ញុំទាំងអស់គ្នា តែគេមិនបាននៅកន្លែងជាមួយខ្ញុំទេ ខ្ញុំបាននៅកន្លែងរាងខ្ពស់ជាងគេបន្តិច!

ដានីៈ អ៎កាលហ្នឹងពូបាននៅកន្លែងខ្ពស់ជាងគេ?

ជឿនៈ ខ្ញុំបានម៉ោនៅកន្លែងគៀកអ៊ំ គេទៅតាមក្រុមតូចៗណា៎!

ដានីៈ ចុះម៉ោនៅជិតតាអៀង សារី?

ជឿនៈ បាទ!

ដានីៈ ធ្វើអីកាលហ្នឹង?

ជឿនៈ កាលហ្នឹងទទួលខាងបញ្ជី!

ដានីៈ ជំនួយការគាត់ឬក៏?

ជឿនៈ អត់ទេ! ជាអគ្គភាពគេហៅអគ្គភាពបបូរ ដល់ធ្វើការកន្លែងមួយនោះមិនបានគេបញ្ជូលខ្ញុំទៅកន្លែងផ្សារហ្នឹង ។

ដានីៈ អ៎កន្លែងផ្សារ?

ជឿនៈ បាទ!

ដានីៈ ផ្សារអូរឫស្សី?

ជឿនៈ វាអត់ចំផ្សារអូរឫស្សីទេវាជាប់ផ្សារធំថ្មី!

ដានីៈ អ៎វាជាប់ផ្សារថ្មីវិញ?

ជឿនៈ បាទ! កន្លែងហ្នឹងផ្ទះនៅសព្វថ្ងៃនេះឯង អាផ្ទះកែងអូរឫស្សីហ្នឹង អាផ្ទះ៧ជាន់ហ្នឹង ផ្ទះហ្នឹងគេយកធ្វើកន្លែងផ្សារអន្តរជាតិ ។

ដានីៈ គេលក់អីខ្លះ?

ជឿនៈ គេលក់គ្រប់មុខ!

ដានីៈ លក់គ្រប់មុខ?

ជឿនៈ បាទ! មានតាំងពីម្ហូបអាហារ មាស ហើយហ្នឹងស្អីគ្រប់មុខ ។

ដានីៈ សម្រាប់លក់ឲ្យពួកណា?

ជឿនៈ និយាយរួមពួកប្រទេសក្រៅគេទៅគេចូលទិញទាំងអស់ហ្នឹង!

ដានីៈ ប៉ុន្តែខ្មែរយើងអត់មានទេ?

ជឿនៈ ខ្មែរយើងអត់មានទេ ខ្មែរយើងគ្រាន់តែជាអ្នកលក់ដូរ!

ដានីៈ គ្រាន់តែជាអ្នកលក់ដូរទេ?

ជឿនៈ បាទ!

ដានីៈ ពីអ្នកលក់ដូរហ្នឹងមែន?

ជឿនៈ ខ្ញុំមិនមែនជាអ្នកលក់ដូរទេ ខ្ញុំជាអ្នកកាន់បញ្ជី!

ដានីៈ ពូជាអ្នកកាន់បញ្ជី?

ជឿនៈ ដូចថាគេយកអីម៉ោៗថ្លឹងកន្លែងខ្ញុំ ខ្ញុំធ្វើបញ្ជីឲ្យគេទៅ។

ដានីៈ កាលហ្នឹងមានហាងឆេងមានអីម៉េចៗទេ គេមានប្រាប់ទេ?

ជឿនៈ មាន! កាលនោះខ្ញុំអ្នកវៃឈ្មោះរបស់ទូទៅរបស់ម៉ាទូទៅស្រុកខ្មែរយើងហ្នឹង ដាក់ម៉ាថ្លៃដាក់អីខ្ញុំអ្នកដាក់ទាំងអស់ ហើយឲ្យអ៊ីជាអ្នកសម្រេច ដល់ខ្ញុំដាក់ប៉ុន្មានៗអ៊ីគាត់ថាត្រូវទាំងអស់។

ដានីៈ អ៊ីណាជាអ្នកសម្រេច?

ជឿនៈ អ៊ីអៀង សារី អ៊ីប៉ុល ពតអីហ្នឹង!

ដានីៈ ចុះពូដាក់តម្លៃហ្នឹងពូមើលតាមអី?

ជឿនៈ ខ្ញុំស្មានតាមរបស់យើងដូចថាជាគ្រឿងបន្លែបន្ថាអ៊ី ខ្ញុំសរសេរមានរបៀបវាដូចថាបន្លែមានមួយឈុតវាបន្លែ សាច់ដាក់មួយឈុតសាច់ត្រី ហើយសម្ភារៈយើងដូចជាកង់ម៉ូតូនឹងយើងដាក់ទាំងអស់ហ្នង ដាក់រៀបវាហើយយើងដាក់តម្លៃទៅ តម្លៃលុយរៀលហើយហ្នឹងលុយដុល្លា។

ដានីៈ មានដាក់លុយដុល្លាដែរ?

ជឿនៈ គេបង់ៗលុយដុល្លាទាំងអស់ ប៉ុន្តែយើងវៃតម្លៃជាលុយរៀល លុយរៀលយើងនៅចាំបានរាល់ថ្ងៃជាសម័យនោះហ្នឹងយើងថ្លៃដែរហ្នឹង!

ដានីៈ ថ្លៃ?

ជឿនៈ តែ៣រៀល៤កាក់ទេមួយដុល្លាហ្នឹង!

ដានីៈ បាទ!

ជឿនៈ គេកំណត់ថាថ្លៃអញ្ចឹងហ្នង ពួកបរទេសគេត្រវីក្បាលគេថាថ្លៃណាស់ តែយើងអត់ទាន់សម្រេចចាយលុយណាទេព្រោះតាមខ្ញុំដឹងកាលហ្នឹងពួកអ៊ីកាលហ្នឹងប្រទន់ប្រទាញគ្នាដែរ មួយថាលុយឈប់ចាយហើយធ្វើលុយធ្វើអី ហើយមួយទៀតថាយើងអត់ចាយលុយមិនកើតទេ ប្រជាជន

យើងមិនចាយលុយមិនកើតទេ ដល់ពេលអញ្ចឹងវានៅរគាក់រគាំដែរហ្នឹង ហើយយើងនៅក្មេងដែរ!

ដានី៖ អ៊ំណាដែលចង់ឲ្យចាយលុយ?

ជឿន៖ អ៊ំចង់ឲ្យចាយលុយអ៊ំអៀង សារី ព្រោះអ៊ំអៀង សារីគាត់អ្នកបោះលុយពីចិនម៉ោបង្កើតលុយរៀលយើងម៉ោវិញ ហើយលុយបើតាមខ្ញុំដឹងដល់ខាងនេះគេបដិសេធមិនឲ្យចាយគេទម្លាក់ទៅខាងស៊ឹងត្រង់ ហើយទៅអូរម្លូដែរ!

ដានី៖ អូរម្លូ?

ជឿន៖ កន្លែងហ្នឹងជាមូលដ្ឋានចាស់មួយដែរហ្នឹងយកទៅចោលហ្នឹង លុយហ្នឹងដឹកកប៉ាល់ទៅចោលហ្នឹង!

ដានី៖ ដឹកកប៉ាល់ទៅចោលនៅខាងអូរម្លូស៊ឹងត្រង់ហ្នឹង?

ជឿន៖ បាទ! យកទៅម្ដុំហ្នឹង ។

ដានី៖ កម្មវិធីរបស់ចាស់ៗ?

ជឿន៖ បាទ! ហើយអ្នកមិនឲ្យចាយនោះវាច្រើនដែរ!

ដានី៖ អ៊ំណាខ្លះដែលគាត់មិនចង់ឲ្យចាយ?

ជឿន៖ និយាយរួមច្រើនណាស់! គេថាយើងឈប់ចាយហើយឲ្យវាឈប់ទៅ ។

ដានី៖ កាលហ្នឹងពូស្គាល់អ៊ំអៀង សារីច្បាស់ទេ?

ជឿន៖ ច្បាស់!

ដានី៖ ហើយកាលហ្នឹងគាត់ស្គាល់ពូច្បាស់ទេ?

ជឿន៖ ស្គាល់! ដល់ក្រោយម៉ោពេលដែលខ្ញុំទៅនៅព្រំដែននោះគាត់លែងស្គាល់ហើយ ខ្ញុំក៏មិនសូវរវល់ដែរ ដល់ពេលដែលរត់ម៉ោហើយគាត់លែងស្គាល់ហើយ!

ដានី៖ កាលហ្នឹងស្គាល់គាត់?

ជឿន៖ បាទ!

ដានី៖ ពូអាសាចេញចូលស្គាល់គាត់?

ជឿន៖ បាទ!

ដានី៖ មានបាននិយាយផ្ទាល់មាត់ជាមួយគាត់ដែរទេ?

ជឿន៖ ទៅលេងកន្លែងខ្ញុំតែរហូតហ្នឹង! តែបើជិតស្និទមួយចំនែកនោះតាជួន ជឿនទេខាងវិជ្ជបណ្ឌិត ។

ដានី៖ ម៉េចបានពូទៅស្និទស្នាលជាមួយតាជួន ជឿនវិញ គាត់ខាងពេទ្យហ្នឹង?

ជឿនៈ គាត់ខាងពេទ្យគាត់ចូលទៅបង្កើតនារីបរទេស គាត់ឈឺពោះទៅកើតនៅកន្លែងខ្ញុំហ្នឹងណា៎ ដល់រកកន្លែងបង្កើតគេអត់បានគាត់ទៅបង្កើតនៅហ្នឹង អានេះគេហៅថាមាននិស្ស័យម៉េច គាត់ចេះតែយកម៉ោហើយជួយបង្រៀនខ្ញុំពីវិធីពេទ្យ គាត់ថាមិនជួបគាត់តាំងពីដើម ដល់ពេលម៉ោជួបជួបពេលមានការសំខាន់មិនអាចដកបាន កុំអីគាត់ដកយកទៅនៅជាមួយគាត់ ។

ដានីៈ កាលហ្នឹងពូអ្នក ដូចថាយើងអ្នកធ្វើបញ្ជីនៅផ្សារថ្មី?

ជឿនៈ ធ្វើបញ្ជីហ្នឹងខ្ញុំវាបានមាត់ដែរហ្នឹង!

ដានីៈ យើងបានមាត់បានក?

ជឿនៈ ចេះនិយាយលេងអី ខ្ញុំតែអញ្ចឹងមិនចេះខ្លាចអីម៉េចផង គេថាខ្ទះគេឃើញមិនហ៊ានមើលមុខផង ហើយខ្ញុំថាទៅខ្លាចអីគាត់ គាត់មានធ្វើអីយើង ហើយខ្ញុំដូចថារស់រាយទៅគាត់ចូលចិត្ត ។

ដានីៈ ចុះអ្នកគ្រប់គ្រងនៅផ្សាថ្មីហ្នឹងពីណាគេ?

ជឿនៈ មានមនុស្សស្រី ហើយមានមនុស្សពីលើខ្ញុំហ្នឹងពីនាក់ដែរ ស្រីមួយប្រុសមួយ!

ដានីៈ ពីណាគេហ្នឹង?

ជឿនៈ ក្រោយម៉ោគាត់ស្លាប់ហើយ ឈ្មោះធី!

ដានីៈ ឈ្មោះ ធី?

ជឿនៈ បាទ! គាត់បាញ់ខ្លួនគាត់មិនដឹងគាត់ទឹកអាស៊ីតស្ទុករឿងអី មនុស្សហ្នឹងជនជាតិ ។

ដានីៈ គាត់ស្លាប់នៅណា?

ជឿនៈ ស្លាប់នៅកន្លែងផ្សារហ្នឹងហ្នង?

ដានីៈ គាត់បាញ់តាំងពីជំនាន់បីឆ្នាំ?

ជឿនៈ បាទ! កាលហ្នឹងថាឲ្យគាត់ម៉ោរៀន ដល់ពេលម៉ោរៀនទៅថាគេធ្វើជីវិទស្សតិះទៀនម៉េចទេក៏បកទៅវិញហើយគាត់ផ្តាំផ្ញើខ្ញុំតែមួយម៉ាត់ថាបងមិនបានរកប្រពន្ធមិនបានការប្រពន្ធឲ្យអាអូនឯងទេ គាត់និយាយតែប៉ុណ្ណឹងហើយគាត់ជិះម៉ូតូទៅបាត់ទៅ ដល់ទៅបាត់មួយសន្ទុះឃើញជិះម៉ូតូចូលផ្ទះហើយនៅផ្ទះធម្មតា ដលពេលបងប្អូនគាត់ពូចៀមទៅហៅធីៗព្រំដែស ។

ដានីៈ គាចៀមយើងហ្នឹង?

ជឿនៈ បាទ!

ដានីៈ គាចៀមគាត់ធ្វើអីគេកាលជំនាន់បីឆ្នាំ?

ជឿនៈ គាត់នៅក្រសួងការបរទេសដែរហ្នឹង គាត់ក្នុងបណ្តាញដែលគេថាពីតាអៀង សារីនោះមានតាហុងៗនោះហើយគាត់គ្រប់គ្រងធំៗបន្តបន្ទាប់គ្នាហ្នឹងបីនាក់ហ្នឹង!

ដានី៖ ចុះតាកន?

ជឿន៖ តាកនគាត់អត់មានការងារធំទេ គាត់គ្រាន់តែគ្រប់គ្រងពិធីការទេដែលគេថាបញ្ជីអន្តលីលេខគេ នោះនៅកន្លែងទីស្នាក់ការក្រសួងការបរទេស ។

ដានី៖ ចុះបងប្អូនតាអៀង សារីគាត់គ្រប់គ្រងនៅផ្សារអូរឫស្សីដែរមែន?

ជឿន៖ ទេបងប្អូនតាអៀង សារីខ្ញុំដូចមិនដែលឮថាគាត់មានបណ្តាញបងប្អូនទេ ស្គាល់តែប្តីប្រពន្ធគាត់តែម្តង ។

ដានី៖ ស្គាល់តែប្តីប្រពន្ធគាត់?

ជឿន៖ បាទ! បើខ្សែតាសុន សេនដូចមានបងប្អូនច្រើន! ខ្ញុំដឹងតែតាកន ហើយម្នាក់ទៀតនៅគ្រប់គ្រងនៅចំការធុរេនហ្នឹងអាហ្នឹងប្អូនតាសុន សេនបង្កើត តែបើតាអៀង សារីដូចឮតែគាត់ទោលហ្នឹងខ្ញុំដូចមិនដែលឮដែរហ្នឹង បើដូចក្មួយអីដូចតាហុងដូចគ្រាន់តែជាប់ខ្សែអីធម្មតាទេ ហើយដូចថាតាអៀង សារីនេះគាត់បានប្រពន្ធប្អូនតាប៉ុល ពត ខៀវ ពន់ណារិទ្ធហ្នឹង ។

ដានី៖ ខៀវ ពន់ណារីគាត់ត្រូវជាប្អូនប្រពន្ធរបស់អៀង សារី?

ជឿន៖ វាដូចវិនវ៉ាយគ្នាម៉េចទេ ខ្ញុំមិនសូវដឹងរឿងច្បាស់ដែរ!

ដានី៖ ហើយហុងគាត់ក្មួយរបស់តាអៀង សារី ដូចក្មួយតាប៉ុល ពតស្អី សូ សួង អាហ្នឹងដឹងតែមានបងកូនហ្នឹងតាហុងហ្នឹងហ្នង អាហ្នឹងបងប៉ុល ពតហ្នឹងទៀត!

ជឿន៖ បងរបស់ប៉ុល ពត?

ដានី៖ បាទ!

ជឿន៖ ហុងហ្នឹងកូនរបស់បងប៉ុល ពតហ្នឹងទៀត អញ្ចឹងគាត់ត្រូវក្មួយ ។

ដានី៖ អញ្ចឹងពូនៅគ្រប់គ្រងនៅកន្លែងផ្សារថ្មីហ្នឹងរហូតទាល់តែបែក៧៩?

ជឿន៖ បាទ!

ដានី៖ ពូនៅធ្វើបញ្ជីហ្នឹងរហូត?

ជឿន៖ បាទ! គិតបញ្ជីទទួលការបរទេសបង់លុយណាឲ្យម៉ោខ្ញុំ ដលពេលខ្ញុំបានលុយហើយខ្ញុំឡើងយកទៅឲ្យ!

ដានី៖ យកទៅឲ្យអ្នកណាគេ?

ជឿន៖ យកទៅឲ្យតាអៀង សារី! ឡើងអត់ទាន់ហើយរត់ហ្នឹងសល់លុយប៉ុន្មានសែនដុល្លាខ្ចប់ឲ្យនារីមួយកាន់ហ្នងទៅ! ខ្ចប់ក្រណាត់ហើយរុំកៅស៊ូខាងក្រៅ ថង់ប៉ុណ្ណេះដែរហ្នឹង! ហើយនារីហ្នឹងខ្ញុំសួរទៅថាទម្លាក់ចោលនៅតាគង់នោះព្រោះប្រុសៗដេញ គាត់រត់ម៉ោដល់តាគង់នោះ ។

ដានី៖ គាត់គង់ហ្នឹងនៅណា?

ជឿន៖ គាត់គង់យើងនៅក្រោយអង្គត់សនេះ!

ដានី៖ អញ្ចឹងលុយហ្នឹងមានឃើញទេអញ្ចឹង?

ជឿន៖ ថាចោលនៅហ្នឹង ព្រោះលុយហ្នឹងឡើងអត់ទាន់សភាពការណ៍ប្រែប្រួលទៅពួកខ្ញុំឆក់កាំភ្លើងបាញ់ព្រោងព្រាតផ្ទុះក្នុងក្រុង!

ដានី៖ ចុះលុយមុនៗ?

ជឿន៖ លុយមុនៗយើងឡើងឲ្យគាត់អស់ ។

ដានី៖ អញ្ចឹងដូចថាតម្លៃទំនិញអីហ្នឹងពូដាក់ខ្លួនឯងទេ?

ជឿន៖ ខ្ញុំគ្រាន់តែសរសេរឈ្មោះទេមិនមែនខ្ញុំជាអ្នកសម្រេចទេ សរសេរឈ្មោះតម្លៃវើយកទៅឲ្យព្រោះនៅកន្លែងខ្ញុំហ្នឹងមិនមែនមានតែខ្ញុំទេ បើគិតទៅមិនមែនអ្នកចេះទេប៉ុន្តែបើខ្ញុំគ្រប់គ្រងព្រោះមនុស្សគេសុទ្ធតែចេះ សុទ្ធតែនិស្សិតជន និស្សិតបញ្ញាវ័នច្រើនធ្វើការជាមួយខ្ញុំ!

ដានី៖ បាទ!

ជឿន៖ ខ្ញុំគ្រាន់តែថា បើនិយាយរួមខ្ញុំគ្រាន់តែជាអ្នកចាត់ចែងហុចតែក្រដាសវ៉ាមម៉ោ ឥលូវធ្វើបញ្ជីដាក់ឈ្មោះតម្លៃនេះប៉ុណ្ណេះៗខ្ញុំសរសេរដែរតែសរសេរដៃ ហើយយកទៅឲ្យគេវើក្រោយម៉ោគេធ្វើបានដូចគ្នាហ្នឹង ។

ដានី៖ តែពូធ្លាប់មានបទពិសោធន៍?

ជឿន៖ រឿងរកឃើញដូចគ្នាតែខ្ញុំអត់ចេះអក្សរអង្គ្លេសផងតែខ្ញុំវើអក្សរអង្គ្លេសបានដូចតែគ្នា ដល់មើលដឹងទៅវាអត់មានលើកដាក់បន្តក់អីដូចខ្មែរយើងផង វាស្រួលជាង!

ដានី៖ អង្គ្លេសពូវៃបានដែរ?

ជឿន៖ វៃបាន!

ដានី៖ អត់ចេះអង្គ្លេសតែវៃបាន?

ជឿន៖ វៃបាន តែវើហ្នឹងក៏មានរៀនបណ្តើរៗហ្នឹងគេដែរព្រោះពួកនិស្សិតហ្នឹងគេស្រលាញ់ខ្ញុំណាស់គេជួយបង្រៀន ។

ដានី៖ គេធ្វើការជាមួយរហូតឬក៏គេមានផ្លាស់ទៅធ្វើការនៅណា?

ជឿន៖ នៅធ្វើហ្នឹងរហូត! ទើបតែ៧៩ហ្នឹងរត់ជាមួយគ្នាហើយបែកគ្នាអស់មិនដឹងរត់ទៅណាអស់ ។

ដានី៖ ពូស្គាល់អត់?

ជឿន៖ ស្គាល់ តែអាមួយម៉ោស្លាប់នៅព្រំដែនម៉ាឡៃនេះឯង! អាហ្នឹងអ្នកនៅជាប់ឈ្មោះ ខាន់ ។

ដានី៖ ខាន់ហ្នឹងគាត់ចេះច្រើន?

ជឿន៖ បាទចេះច្រើន!

ដានី៖ ពូមួយទៀតដែលខ្ញុំចង់ដឹងកាលជំនាន់បីឆ្នាំហ្នឹង ពូមានធ្លាប់បានជួយពីណាដែលគាត់មានបញ្ហាដូចថាគាត់ត្រូវគេចាប់អីហ្នឹងពូមានធ្លាប់បានជួយសង្គ្រោះជីវិតពីណាដែរអត់កាលជំនាន់បីឆ្នាំហ្នឹង?

ជឿន៖ ខ្ញុំមិនដែលជួបដែរព្រោះភាគច្រើនខ្ញុំនៅតែក្នុងផ្សារ! ហើយទោះបីគេចាប់ក៏មិនមែនកន្លែងខ្ញុំដែរកន្លែងខ្ញុំមិនដែលឮចាប់អ្នកណាទេ កាលហ្នឹងឮមួយឈ្មោះ រឿន ប្រពន្ធគា ខឿនហ្នឹងគេត្រូវចាប់នៅផ្សារដែរហ្នឹងតែគេម៉ោធ្វើការចាប់នៅផ្សារហ្នឹងហ្នង
គេនាំទៅរៀនទៅអីហើយបាត់ទៅរហូត គេធ្វើការវិនិច្ឆ័យថាគេចាប់គាត់ហើយ រួញដែរទាំងគេទាំងខ្ញុំនិយាយអីគេបាន ដូចថាចេះលាក់ការហើយការពារខ្លួនរៀងខ្លួន ។

ដានី៖ រឿន ប្រពន្ធ?

ជឿន៖ ថាប្ដីឈ្មោះ ខឿន! រឿន ហ្នឹងស្រីទេ!

ដានី៖ តែ ខឿន ហ្នឹងប្ដីគាត់!

ជឿន៖ គាត់ហ្នឹងធំណាស់!

ដានី៖ គាត់ធ្វើនៅ៨៧០មែន?

ជឿន៖ បាទ!

ដានី៖ ពូស្គាល់មន្ទីរ៨៧០ទេ?

ជឿន៖ មិនសូវដែលហ៊ានចូលទេ!

ដានី៖ តែទីតាំងវានៅកន្លែងណាមន្ទីរ៨៧០?

ជឿន៖ នៅភ្នំពេញហ្នឹង?

ដានី៖ បាទនៅភ្នំពេញ!

ជឿន៖ ជិតតែវាំងហ្នឹងដែរហ្នឹង សព្វថ្ងៃបើតាមខ្ញុំមើលទៅដូចជាហ៊ុន សែនទៅនៅម្តុំហ្នឹងដែរ!

ដានី៖ កន្លែងណាទៅ?

ជឿន៖ កន្លែង៨៧០ហ្នឹងដែរ!

ដានី៖ កន្លែងវាំងមានក្រសួងយុត្តិធម៌ នៅនេះមានព្រឹទ្ធសភា!

ជឿន៖ អត់ទេវានៅគាកវិមានឯករាជ្យវិញ!

ដានី៖ នៅគាកវិមានឯករាជ្យវិញ?

ជឿនៈ បាទ! តែក្នុងកំឡុងពីមុខដែលយើងមានទន្លេអញ្ចឹងតែវាពីក្រោយ ព្រោះវាំងវានៅខាងជើងអញ្ចេះ វានៅម៉្លឹងហ្នឹង ។

ដានីៈ ពូនៅចាំទេបើទៅភ្នំពេញវិញ?

ជឿនៈ ខ្ញុំជិះឡានទៅម្ដងហើយតែខ្ញុំមើលអត់ចំនាំទេ!

ដានីៈ អត់ចំនាំបានទេ?

ជឿនៈ បាទព្រោះវាប្រែកដែរ សូម្បីតែគេតែងតួផ្លាក៏ខុសពីមុនដែរ ហើយផ្ទះក៏ខុសមុនដែរព្រោះវាខ្ពស់ កាលពីមុនវាមានផ្ទះទាបៗទេណា៎ តែឥលូវវាខ្ពស់ទាំងអស់ ព្រោះគេកែប្រែលឿនដែរ!

ដានីៈ ចុះឈ្មោះរឿនប្រពន្ធគាត់ហ្នឹងអ្នកម៉ោពីណាដែរ?

ជឿនៈ ពីមុនគាត់នៅកំពង់ចាមដែរ!

ដានីៈ គាត់ម៉ោពីខាងកំពង់ចាម?

ជឿនៈ បាទ! គាត់ខាងអ្នកទទួលរោងចក្រដូនគីអីម៉េចទេនៅខេត្តកំពង់ចាម ។

ដានីៈ ចុះដល់ពេលគាត់ម៉ោនេះគាត់ម៉ោធ្វើការជាមួយពូ?

ជឿនៈ បាទម៉ោនៅគ្រប់គ្រងផ្សាររដ្ឋហ្នឹងបានមួយរយៈដែរហ្នឹង ។

ដានីៈ កាលហ្នឹងគាត់គ្រប់គ្រងធំជាងពូមែន?

ជឿនៈ បាទប្រធានផ្សារទាំងមូលហ្នឹងហ្នង!

ដានីៈ ដល់ពេលក្រោយពីគាត់ម៉ោ?

ជឿនៈ ក្រោយពីគាត់ម៉ោមានមនុស្សស្រីម្នាក់ទៀត!

ដានីៈ ឈ្មោះអីគេគាត់ហ្នឹង?

ជឿនៈ ឈ្មោះយាយភាស់!

ដានីៈ គាត់ប្រពន្ធពីណាដែរ?

ជឿនៈ ប្ដីគាត់ធ្វើធំដែរកាលហ្នឹង ស្លាប់ហើយគាត់កើតរោគ! ប្ដីគាត់នៅខាងតាកែវ ។

ដានីៈ ធ្វើខាងអីប្ដីគាត់?

ជឿនៈ កាលសម័យនោះដូចជាគណៈតំបន់អីក៏អីទេខ្ញុំភ្លេចឈ្មោះ! ប៉ុន្តែមនុស្សហ្នឹងរត់ម៉ោអាចស្លាប់តាមផ្លូវព្រោះគាត់មានរោគាំ ។

ដានីៈ តំបន់នៅណា ជាមួយតាមុកដែរមែន?

ជឿនៈ ជាមួយតាមុកប្ដីគាត់!

ដានីៈ បាទ! គាត់រហូតដល់បែក៧៩ហ្នង?

ជឿនៈ បាទ! យាយភាស់ហ្នឹងគាត់ស្រួលណាស់ កាលគាត់កាន់ហ្នឹងសភាពការណ៍វាលែងមានអាញ៉ៅ អាញ៉ៅអីហើយ ដូចថាស្រួលទៅហើយ!

ដានីៈ ចុះបន្ទាប់ពីឈ្មោះ ធី គេបាញ់សម្លាប់ចោលហ្នឹងហើយមានអ្នកផ្សេងម៉ោជំនួស?

ជឿនៈ ហ្នឹងអើយយាយភាស់ហ្នឹងឯងបន្តពី ធី ហ្នឹង!

ដានីៈ អ៊ំ!

ជឿនៈ ធី ហ្នឹងតពីរឿន!

ដានីៈ ធី ហ្នឹងតពីរឿនហើយបានយាយភាស់?

ជឿនៈ បាទ!

ដានីៈ ចុះពូកាលជំនាន់ហ្នឹងដូចថាធ្លាប់បាននេះ ដល់ពេលរត់ម៉ោមានធ្លាប់បានជួយពីណាផ្សេងដូចជាឲ្យបាយឲ្យទឹកឬក៏គេសុំអីពូជួយគេមានដែរអត់ទេតាំងជំនាន់បីឆ្នាំកាលពូរត់?

ជឿនៈ មានខ្លះដែរ!

ដានីៈ មានខ្លះដែរ?

ជឿនៈ បាទ! សូម្បីតែនៅពេលនៅទាហានដែលចប់ភ្លាមហ្នឹងខ្ញុំធ្លាប់ជួយដែរហ្នឹង ខ្ញុំធ្លាប់ឲ្យអង្ករ ដូចថាគេជម្លៀសពីភ្នំពេញពីអីពីខេត្តខ្ញុំហ្នឹង ខ្ញុំនៅខាងខេត្តដល់ពេលនេះគេឲ្យខ្ញុំចេញម៉ោការពារនៅកន្លែងមួយការពារឃ្លាំងដល់ហើយប៉ះអ្នកជម្លៀសហ្នឹងខ្ញុំឲ្យអង្ករគេឡើងជិតអស់ពីខ្លួន ។

ដានីៈ កាលហ្នឹង៧៥មែន?

ជឿនៈ បាទ៧៥ហ្នឹងខ្ញុំជួយម៉ាសា ដល់ក្រោយម៉ោឆ្នាំ៧៩ហ្នឹងបានម៉ោតាមផ្លូវមានទៀតតែច្រើនតែក្មេងស្រីតូចៗដែលរត់ទៅបែកម៉ែឪអីហ្នឹង អាហ្នឹងខ្ញុំជួយដែរហ្នឹង!

ដានីៈ ជួយម៉េចទៅ?

ជឿនៈ ឲ្យអង្ករឲ្យអី ហើយដូចថាខ្ញុំមានស្គាល់គេអញ្ជើងខ្ញុំយកទៅផ្ញើររហូតម៉ោ ខ្លះនៅកណ្តាលព្រៃយើងព្រំដែននេះទៀតក្មេងស្រីអាហ្នឹងយើងយកជាប់ហ្នឹង ។

ដានីៈ ឈ្មោះអីគេ?

ជឿនៈ ភ្លេចឈ្មោះវាទៀតណា៎!

ដានីៈ ឥលូវនៅរស់ដែរអត់?

ជឿនៈ អត់ដឹង! ខ្ញុំឲ្យអ៊ំបង្កើតទៅសួរវាថាអ៊ំបង្កើតថាអ៊ំខ្ញុំ តែវារត់ចោលខ្ញុំម្តងហើយ វាហៅតែបងៗ ។

ដានីៈ កាលហ្នឹងពូជួយពីកន្លែងណាដល់កន្លែងណា?

ជឿនៈ ឆ្ងាយដែរតាំងពីយើងភ្នំខៀវរហូតម៉ោដល់ជើងគ្រាងនេះ អៀវកវាម៉ោរហូត!

ដានីៈ ពូអ្នកអៀវមែន?

ជឿនៈ ខ្ញុំអ្នកអៀវក្មេងហ្នឹង!

ដានីៈ ក្មេងហ្នឹងប៉ុណ្ណា?

ជឿនៈ តូចដែរ! កាលហ្នឹងវាធំជាងចៅខ្ញុំមីបងបន្តិចហ្នឹង! ដល់ក្រោយម៉ោវាដើរបានធ្វើបាយហូបធ្វើអី

ដានីៈ ហើយនៅជាមួយពូបានយូទេ?

ជឿនៈ យូដែរ៥,៦ខែបានម៉ោជួបអ៊ំគេនៅជើតត្រាំង ហើយអ៊ំគេបានឆ្លើយថាខ្ញុំទៅជំរុំហើយសុំក្មួយទៅវិញ មុនដំបូងនៅជាមួយខ្ញុំៗធ្វើកងទ័ពខ្ញុំផ្ញើរកន្លែងដឹកជញ្ជូនពេលខ្ញុំម៉ោក្រោយខ្ញុំម៉ោលេង!

ដានីៈ ក្មួយហ្នឹងពូអត់ចាំឈ្មោះទេ?

ជឿនៈ ចាំ! កាលហ្នឹងឈ្មោះ សុថន!

ដានីៈ ស្រី?

ជឿនៈ បាទ! តែសព្វថ្ងៃមិនដឹងទៅដល់ណា!

ដានីៈ ចុះគេមាននិយាយប្រាប់ថាឪពុកម្តាយគេយ៉ាងម៉េចដែរអត់?

ជឿនៈ គេថាឪពុកម្តាយគេបែកតាំងពីយើងត្រកែនសាំងយើងគឺឡូវលេខ៦ហ្នឹង!

ដានីៈ អ៎!

ជឿនៈ ថាបែកកន្លែងហ្នឹង ថាឪពុកម្តាយវានៅធ្វើការនៅកន្លែងហ្នឹង!

ដានីៈ ធ្វើការនៅកន្លែងហ្នឹង?

ជឿនៈ បាទ! ហើយវារត់ម៉ោជាមួយគេជាមួយឯងហ្នឹង! ដល់ពេលម៉ោជួបអ៊ំ ហើយគេថាទៅជាមួយអ៊ំដល់ពេលវាឈឺទៅអ៊ំទុកចោលទៅ ហើយខ្ញុំឃើញមើលទៅស្គាបទៅវាមិនទាន់ដាច់ខ្យល់ហើយយកទៅសាលាកើតទៅវារាងដឹងខ្លួនបើកភ្នែកទៅស្រណោះគ្នាមិនដឹងធ្វើម៉េចមានតែអៀវកម៉ោហ្នុងទៅ ទៅឆ្ងាយដើរកន្លះខែនោះ!

ដានីៈ ចុះមានជួយពីណាទៀតទេ?

ជឿនៈ ធ្លាប់ជួបតែមួយហ្នឹងឯង!

ដានីៈ ចុះកាលពីឆ្នាំ៧៥កាលពូធ្វើកងទ័ពពេលហ្នឹងអ្នកជម្លៀសម៉ោខាងកំពង់ឆ្នាំងហ្នឹងមែន?

ជឿនៈ គេម៉ោដើរកាត់ខត្តុងម៉ោនៅក្រោយខត្តុងកាលហ្នឹង ឃ្លាំងអីទេ ឃ្លាំងសម្ងាត់គេហើយមានអង្ករមួយឃ្លាំងដែរហ្នឹង ស្រណោះខ្លះឃើញមានស្ពាយតែលុយ ហើយខ្ញុំថាលុយហូបអត់កើតទេអត់មានអីទិញទេទៅហ្នឹង ហើយតាមទិសដៅដូចគេឲ្យម៉ោណាទេម៉ោលើដែរហ្នឹង!

ដានីៈ បាទ! ពូស្រណោះម៉េចបានពូឲ្យអង្ករ?

ជឿនៈ ដូចថាវាអត់មានឃើញមានអី ហើយទៅសុំបាយហូប ហើយពួកខ្ញុំនៅមួយក្រុមហ្នឹង នៅរយៈពេលខ្លីដែរហ្នឹងនៅ៣,៤ថ្ងៃហ្នឹងប៉ុន្តែមនុស្សវាច្រើនដើរឡើង៣ថ្ងៃបានអស់ឃើញផុតពីកន្លែងខ្ញុំរឃើរឃាកមានឃើញចានឆ្នាំង ហើយស្ពាយតែខោអាវ!

ដានីៈ បាទ!

ជឿនៈ ហើយខ្វះសន្ទាតតែលុយ ហើយលុយសម័យនោះមានចាយអី!

ដានីៈ បាទ!

ជឿនៈ ហើយអាពេលចប់ក្ងាមអត់មានចាយសោះ ទៅចាយណាបើមិនមានអីទិញផង!

ដានីៈ គេសុំពូក៏ឲ្យទៅ?

ជឿនៈ បាទ!

ដានីៈ ឲ្យច្រើនៗដែរ?

ជឿនៈ ច្រើនដែរ ឲ្យម៉ាល្មមដើរបាន៨,១០ថ្ងៃដែរ!

ដានីៈ ឲ្យច្រើននាក់ដែរឬក៏តែមួយនាក់?

ជឿនៈ ឲ្យ២០,៣០នាក់ដែរហ្នឹង! ប៉ុន្តែឲ្យដូចថាវាមានក្នុងមួយថ្ងៃអញ្ចឹងវាមានកូនចៅអញ្ចឹងឲ្យមួយអញ្ចឹងទៅដូចថាអាការ៉ុងឃើងខ្សៀវដែលអាមេរិចគេដាក់ដីខ្មែរដែលគេហៅច្រកដីធ្វើបារាយណ៍នោះណា់ ការ៉ុងហ្នឹងវានៅថ្មីៗនោះ ច្រកការ៉ុងនោះហើយកាបួចឲ្យទៅព្រោះកាលនោះឃ្លាំងគេរួមៗជង្រុកគេធំដែរ!

ដានីៈ អញ្ចឹងតាំងពីចេញពីផ្ទះម៉ោពូមិនដែលបានទាក់ទងទៅផ្ទះឬក៏ជួប មានធ្លាប់ផ្ដល់អីខ្វះដល់ផ្ទះដែរអត់កាលជំនាន់នោះ?

ជឿនៈ អត់មានបានផ្ដល់អារបស់អីដល់អ្នកផ្ទះទេ ត្រៀមដែរតែវាមិនបានផ្ញើរមិនដឹងថាផ្ញើរទៅតាមណាបើខ្លួនឯងបងមិនឲ្យទៅ មានរបស់ល្អៗតែមិនបានផ្ញើរទៅ ។

ដានីៈ កាលជំនាន់បីឆ្នាំពូជួបបងដែរ?

ជឿនៈ ជួប! កាលហ្នឹងគាត់របួសម៉ោពីព្រំដែន!

ដានីៈ កាលហ្នឹងគាត់ធ្វើកងទ័ព!

ជឿនៈ កងទ័ពនៅណាដែរ?

ដានីៈ ខ្ញុំអត់មានបានសួរអត្តភាពអីគាត់ផង! ដឹងតែគាត់កាលហ្នឹងគេជ្រើសរើសធ្វើកងបច្ចឹម ។

ជឿនៈ ភូមិភាគបច្ចឹម?

ដានីៈ បាទ!

ជឿនៈ គេបញ្ជូនទៅព្រំដែនខាងកើតនោះ ហើយគាត់របួសម៉ោដេកនៅពេទ្យភ្នំពេញ ។

ដានីៈ ពូអត់ដឹងគាត់ធ្វើនោកងពលណាទេ?

ជឿនៈ អត់ទេ!

ដានីៈ ហើយតែម្នាក់ទេបងប្អូន?

ជឿនៈ បាទ! ហើយអ្នកភូមិខ្ញុំរបួសច្រើនណាស់ តែបើបងបង្កើតមានតែម្នាក់ហ្នឹងទេ ហើយប្អូនជីដូនមួយនៅក្នុងភូមិខ្វះ ។

ដានីៈ ចុះពួកគាត់នៅរស់ដល់សព្វថ្ងៃដែរទេ?

ជឿនៈ ស្លាប់អស់ហើយបងខ្ញុំ! គាត់របួសហ្នឹងរបួសមិនអាចរស់បានទេ គាត់របួសដៃហើយរបួសនៅក្នុងនេះ ហើយគេថតមើលទៅគេថាចង់ប៉ុណ្ណេះហើយដាប់វាមិនបានវានៅក្នុងបង់កុកហ្នឹង ពេទ្យដាប់គាត់សន្ធប់ៗ ពេទ្យខ្លាចស្លាប់ចេះតែព្យាបាលត្រដរទៅរហូតដល់ព្រឹត្តិការណ៍ចិនហ្នឹងរត់ហ្មងដល់ហើយថារត់ម៉ោភ្នំខៀវហ្នឹង គាត់លំបាកគាត់ពេកថាហើមជងអីជង មានពាក្យចាស់បុរាណថាគាត់ពិឃាតខ្លួនឯង សម្លាប់ខ្លួនដើម្បីជួយខ្ញុំ ហើយបងមួយទៀតបាត់ហ្នឹងបងគេបង្អស់ គាត់ធ្វើការនៅកំពង់ដែរ ហើយពាក្យបុរាណមួយពោលថាគេឲ្យទៅជាមួយវ៉ានរត អាហ្នឹងបងទីមួយព្រោះគាត់នៅ៨០១ហើយគេថាគេដក១២នាក់ អាស់គេដកមួយកងទៅភូមិភាគឥសាន្ត ហើយអានេះបើតាមប្រវត្តគេស្រាវជ្រាវរកបងខ្ញុំ ។

ដានីៈ ពួក៨១០គេនៅខាងរតនៈគិរី?

ជឿនៈ នៅខាងរតនៈគិរី!

ដានីៈ បងពូមានតួនាទីធំដែរ?

ជឿនៈ មិនដឹងគាត់ធ្វើអីទេ តែអានេះកងទ័ពដូចគ្នាណា៎! តែបើបងទីមួយនោះគាត់ចេះច្រើនណាស់ព្រោះគាត់ធ្លាប់បានរៀននៅវិទ្យាល័យខ្ពស់ដែរ ។

ដានីៈ ចុះពូបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ជឿនៈ អត់ទេខ្ញុំកាលពីសង្គមរៀនតិចមួយហ្នឹង!

ដានីៈ រៀនថ្នាក់ទីប៉ុន្មាន?

ជឿនៈ រៀនថ្នាក់ទី៩!

ដានីៈ អញ្ចឹងកាលជំនាន់ហ្នឹងពូបាត់បងប្អូនពីរនាក់ដែរ?

ជឿនៈ បាត់ម្នាក់តែគេថាស្លាប់នៅភ្នំខៀវនេះឯង!

ដានីៈ អ៎! ភ្នំខៀវ! ហើយម្នាក់ទៀតបាត់?

ជឿនៈ ម្នាក់ទៀតបាត់បងទីមួយ ហើយក្រោពីហ្នឹងទៀតស្លាប់អស់ហើយទាំងប្អូនហ្នឹង!

ដានីៈ បងប្អូនពូប៉ុន្មាននាក់ដែលស្លាប់ហ្នឹង?

ជឿនៈ ទាំងអស់វាបីនាក់ពី៧៩ម៉ោ!

ដានីៈ ពេលបែក៧៩ហើយបាន...?

ជឿនៈ បាទ!

ដានីៈ បីនាក់ទៀត! ស្លាប់ដោយសារមូលហេតុអីកាលហ្នឹង?

ជឿនៈ ខ្ញុំដឹងរឿងទេកាលហ្នឹង!

ដានីៈ គាត់ធ្វើកងទ័ពដែរ?

ជឿនៈ កងទ័ពខាងពេទ្យ បញ្ជូរស់រត់ទៅខាងលិចវិញខាងកំពង់លែងវិញ ហើយបាត់ខ្លួនរហូតមិនដឹងថាស្លាប់ឬម៉េច ។

ដានីៈ អញ្ចឹងកាលជំនាន់នោះគាត់ធ្វើកងទ័ពខ្មែរក្រហមដែរ?

ជឿនៈ បាទ!

ដានីៈ អញ្ចឹងបងប្អូនពូទាំងអស់ស្លាប់អស់ប៉ុន្មាននាក់ទៅ?

ជឿនៈ បើគិតសព្វថ្ងៃនៅផ្ទះវានៅសល់តែតូចៗក្រោយហ្នឹងតែ៣នាក់ទេ ក្រោពីនោះសុទ្ធតែស្លាប់ បើខាងម៉ែចុងខ្ញុំអស់អាលីងអស់៣នាក់ ហើយដល់ខាងខ្ញុំនេះវាអស់ប្អូនស្រី ប្អូនប្រុស បង២នាក់ទាំងអស់៥នាក់!

ដានីៈ ទាំងអស់៥នាក់!

ជឿនៈ បាទ! ទាំងអស់៨នាក់!

ដានីៈ អស់៥នាក់អញ្ចឹងសល់ប៉ុន្មាននាក់ទៅ?

ជឿនៈ នៅស្រុកឥលូវនៅសល់៣នាក់!

ដានីៈ សល់តែ៣នាក់ទេ?

ជឿនៈ បាទ! ប្រុស២ស្រី១!

ដានីៈ អាហ្នឹងបងប្អូនឪពុកតែមួយ?

ជឿនៈ បាទ! តែម្ដាយខុសគ្នា! ម្ដាយជាមួយខ្ញុំមួយស្រី!

ដានីៈ ចុះពូម៉ោដល់សព្វថ្ងៃពូមានដែលព្រឹត្តិ៍មានទាក់ទងនឹងតុលាកាកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

ជឿនៈ ដូចអត់សូវដឹងព្រោះមិនដែលស្ដាប់គេផង!

ដានីៈ ពូដែលចាប់អារម្មណ៍ទេ?

ជឿនៈ មិនសូវចាប់អារម្មណ៍ផង និយាយរួមពីសមារណកម្មហើយខ្ញុំគិតតែពីអារម្មណ៍របស់ខ្ញុំរាល់ថ្ងៃ ខ្ញុំប្រឹងតែពីចំការរបស់ខ្ញុំ រឿងណានាំទៅដឹកកាហេុដើម្បីចង់ដឹងសួចម្ល៊ើយអីខ្ញុំលែងចង់ដឹងអីទាំងអស់!

ដានីៈ ម៉េចបានពូលែងចង់ដឹងអញ្ចឹង?

ជឿនៈ ទោះបីជាខ្ញុំដឹងក៏ខ្ញុំមិនដឹងថាម៉េច សូម្បីតែសព្វថ្ងៃខ្ញុំទៅខេត្តនិយាយលេងសើចគ្នាលេងហ្នឹងខ្ញុំថាចំពោះបើអ្នកម៉ោពីក្រៅខ្ញុំត តែបើថាជិតគ្នាឯងហ្នឹងមិនធ្វើទេព្រោះខ្ញុំដឹងច្បាស់ហើយសព្វថ្ងៃទំនាស់អារឿងមេដឹកនាំចង់បានអំណាចធំហើយឈ្លោះគ្នាឯងអីហ្នឹង ហើយដើរបំផុសបំផុសគេឲ្យជួយអញ្ចឹងដូចទៅមិនរួចទៀតទេ ប៉ុន្តែបើថាពីក្រៅមិនបាច់ពីណាហៅទេ ព្រោះអាហ្នឹងគេចង់បានទឹកដីយើងអាហ្នឹងយើងត្រូវតែធ្វើអញ្ចឹងហ្នង ព្រោះអាហ្នឹងការងារចាំបាច់របស់យើងជាជនកម្ពុជាមួយត្រូវតែការពារហ្នង ក្នុងគ្នាឯងដឹងតែគ្មានចំនេញអីទេងាប់តែគ្នាឯងហ្នឹង ។

ដានីៈ ចុះតាមប្រវត្តតាមអារម្មណ៍របស់ពូផ្ទាល់ពូយល់ឃើញថាយ៉ាងម៉េចដែរចំពោះតុលាការដែលគេបង្កើតហ្នឹង?

ជឿនៈ ខ្ញុំវាមិនដែលចាប់អារម្មណ៍ផងថាតុលាកាហ្នឹងគេចង់វិនិច្ឆ័យថាយ៉ាងម៉េច ហើយម្យ៉ាងទៀតដែលឮគេនិយាយច្បាស់ថាសម័យហ្នឹងគេទុកខ្មែរក្រហមជាឃាតករហើយ សម្លាប់មនុស្សដល់ទៅ ២,៣លាននាក់នោះ!

ដានីៈ បាទ!

ជឿនៈ តែនៅតែខ្ញុំមិនសូវយកចិត្តទុកដាក់ ខ្ញុំថាមិនដឹងគេយកអ្នកណាទៅដាក់គុក ហើយតាៗហ្នឹងខ្ញុំឲ្យតម្លៃខ្លួនឯងហើយបើតាមខ្ញុំយល់ ខ្ញុំថាគាត់ក៏មិនអាចរស់បានប៉ុន្មានឆ្នាំដែរកាត់មិនទាន់ចប់ផងអានេះងាប់មុនបាត់ទៅហើយ យកទៅដាក់ផ្នូរទៅ អាហ្នឹងខ្ញុំមានអារម្មណ៍អញ្ចឹងទៅវិញណា៎!

ដានីៈ បើតាមអារម្មណ៍របស់ពូ ពូគិតថាតាៗហ្នឹងមានកំហុសដែរអត់ ហើយពូជឿថាការសម្លាប់៣ឆ្នាំហ្នឹងមានមនុស្សស្លាប់ច្រើនដូចគេនិយាយរាល់ថ្ងៃនេះឬអត់?

ជឿនៈ បើតាមខ្ញុំធ្លាប់ឆ្លងកាត់ហ្នឹងវាមិនអាចដល់ថ្នាក់ហ្នឹងទេ ព្រោះដែលច្របូកច្របល់ខ្លាំងតាមដែលខ្ញុំដឹងហ្នឹងពីខ្មែរដែលគេហៅថាខ្មែរភាគជើងនោះ ព្រោះគេហ្នឹងគេទៅនិស្សិយើងដែរហ្នឹង ប៉ុន្តែគេទៅរៀននៅស្រុកយួន ដល់ពេលគេរៀនទៅគេចេះទៅគេមិនចង់ធ្វើតូចណា៎ អាហ្នឹងដែលខ្ញុំដឹងពីប្រវត្តហ្នឹងណា៎ គេហៅថាភាគជើងហ្នឹងគេនិយាយខ្មែរលែងច្បាស់ហើយ ហើយយើងឲ្យទៅរៀនកាលនោះដូចថា២៨០០ឬក៏២០០៥ ដល់ពេលព្រឹត្តិការណ៍ពួកខ្ញុំនេះឈ្នះព្រឹបថ្ងៃ១៧មេសាភ្លាមខាងលើគេលើកនយោបាយមួយថាយើងខ្វះកម្មាភិបាលដឹកនាំ អត់មានអ្នកចេះគ្រប់

គ្រាន់ទេ ដល់ពេលអញ្ចឹងបើតាមខ្ញុំដឹងវាគ្រាន់ថាមិនអ្នកចេះអីទេ ដល់ពេលអញ្ចឹងគេថាត្រូវយក និស្សិតម៉ោពីវៀតណាមយកមកធ្វើអ្នកដឹកនាំតាមភូមិ អានេះខ្ញុំគិតមើលដូចក្រោយម៉ោខ្ញុំរាង ដឹងរឿងគេតុលាកា វាមានឯណាដល់ទៅប៉ុន្មានពាន់នាក់នោះទេ នៅក្នុងមួយខេត្តៗ នៅក្នុងខេត្ត ពួកខ្ញុំគេយកទៅទាំងអស់ បើតំបន់គេមិនអាចទេបើនៅស្រុក..!

ដានី៖ ពូម៉េចដឹងបើពូមិនដែលម៉ោផង?

ជឿន៖ ព្រោះខ្ញុំនៅធ្វើសង្គ្រាមសម័យនោះ ខ្ញុំមិននៅក្នុងខេត្តមែនតែគ្រាន់តែបណ្តាញពីបងប្អូនខ្ញុំដឹងគ្នា ទាំងអស់ ហើយសួតែអ្នកណាធ្វើមេឃុំមេអីក៏ខ្ញុំដឹងដែរ ដូចឃុំខ្ញុំគេហៅអាគីវុធហ្នឹងនិយាយខ្មែរ អត់ច្បាស់ទេ និយាយដូចសម្លេងយួនទាំងអស់ហ្នឹងហើយគេធ្វើមេឃុំហ្នឹង! ហើយមានបណ្តាញ តាមភូមិតាមអីគេក៏ច្រើនតែពួកគេហ្នឹងដែរ! ដល់អញ្ចឹងពេលដែលខ្ញុំទៅលេងស្រុកដំបូងពេល យើងសមារណកម្មហើយហ្នឹងពិបាកអីបងប្អូនខ្ញុំនិយាយប្រាប់ខ្ញុំទាំងអស់ ហើយនិយាយខ្ញុំដឹង ហ្នឹង អ្នកណាធ្វើម៉េច អ្នកណាប្រមូលមាសពីប្រជាជនយកទៅណាខ្ញុំដឹងទាំងអស់ហ្នឹង

ដានី៖ អ្នកណាអ្នកប្រមូល?

ជឿន៖ អាប៉ិមុតហ្នឹង ថាសព្វថ្ងៃទៅបើកហាងនៅខេត្តកំពង់ចាមនោះ ។

ដានី៖ អញ្ចឹង?

ជឿន៖ មាសដែលប្រមូលម៉ោពីឃុំខ្ញុំហ្នឹង!

ដានី៖ អ៎! គាត់អត់មាននៅហ្នឹងទេ?

ជឿន៖ ក្រោយម៉ោគេមាននៅហ្នឹងណា ប្របូកប្របល់គេគេចគេចឡើងថាទៅនៅឯកំពង់ចាមនោះ ហើយថាមានអតីតមានអ្នកប្រដាល់មួយគេហៅសិតប៉ានោះ ប៉ុន្តែគាត់ទៅនៅភូមិខ្ញុំគេហៅតែ តាប៉ាៗ គាត់តាមទៅរកសង់សឹកអាប៉ិមុតហ្នឹងទៀត ប៉ុន្តែឥលូវគាត់ចាស់ជ្រុលហើយ ប៉ុន្តែ គាត់នៅកំពង់ធំដែល គាត់ខឹងដែរហ្នឹង!

ដានី៖ តាប៉ាហ្នឹងគាត់ខឹងរឿងអីគាត់?

ជឿន៖ ខឹងអារឿងដកហ្នឹងហើយធ្វើបាបប្រជាជនអីហ្នឹង ប៉ុន្តែគាត់រស់នៅក្នុងឃុំនេះ ក្រោយពីគាត់ អាម៉ាស់មុខចេញពីប្រដាល់គាត់ភាសខ្លួនទៅនៅស្រុកខ្ញុំហ្នឹងគាត់ទៅយកប្រពន្ធយកកូននៅហ្នឹង!

ដានី៖ តែមុតហ្នឹងគាត់នៅកំពង់ចាម គាត់មានទេ?

ជឿន៖ ប៉ិមុតហ្នឹងពូថាមានពូអ្នកភូមិខ្ញុំនិយាយប្រាប់ ចុះបើមាសមិនដឹងប៉ុន្មានថាប្រមូលយកអស់ ។

ដានី៖ អញ្ចឹងគាត់ទៅបើកហាងនៅកំពង់ចាម?

ជឿន៖ បាទថាបើហាងលក់មាស!

ដានី៖ នៅផ្សារណា?

ជឿន៖ ថានៅក្នុងខេត្តៗ តែខ្ញុំវាមិនដែលបានទៅដែរ!

ដានី៖ កាលហ្នឹងគាត់ធ្វើមេឃុំនៅណា?

ជឿន៖ គាត់ធ្វើមេឃុំនៅភូមិចំណូក!

ដានី៖ គាត់ធ្វើរហូតដល់បែកឆ្នាំ៧៩?

ជឿន៖ បាទ!ទាល់តែរត់៧៩ហ្នឹង គាត់អត់រត់ម៉ោជាមួយពួកខ្ញុំផង!

ដានី៖ អត់រត់ម៉ោជាមួយពួកពូទេ?

ជឿន៖ បាត់ខ្លួន ប៉ុន្តែកាលខ្ញុំទៅលេងស្រុកស្ងួចុះឡើងទៅគេថាឥលូវហ្នឹងបានមាសមិនដឹងប៉ុន្មាន ឥលូវទៅលក់មាសនៅខេត្តកំពង់ចាមនោះ ខ្ញុំឮតែប្រជាជនថាអញ្ចឹង ខ្ញុំថាមិនបាច់ទៅរករឿងអីទេគេសំណាងគេត្រូវបានហើយ ។

ដានី៖ បាទអញ្ចឹងខ្ញុំអរគុណពូច្រើនដែលបានសំណេះសំណាលទាក់ទងនឹងជីវិតរបស់ពូ ។

ជឿន៖ ខ្ញុំសព្វថ្ងៃខ្ញុំលែងចង់ដឹងពីអីទៀតហើយខ្ញុំគិតតែពីជីវភាពរបស់ខ្ញុំប៉ុណ្ណោះ ហើយអារឿងពីក្រោពីលិចអីចេះតែគិតដែរហ្នឹងណា៎ ដល់ឯងម៉ោធ្វើទៀត ។

ដានី៖ ពូចាស់ហើយពូនៅចង់ធ្វើទៀត?

ជឿន៖ អាហ្នឹងចាំបាច់ត្រូវតែធ្វើដើម្បីទឹកដីយើង ព្រោះកម្លាំងយើងនៅមានវាលំបាកមានលំបាកណា៎!

ដានី៖ ពូមានអីចង់បន្ថែមទៀតទេ ក្រៅពីអ្វីដែលខ្ញុំបានសួពូ?

ជឿន៖ ដូចអត់មានចង់និយាយអីទៀតទេ!

ដានី៖ អញ្ចឹងខ្ញុំអរគុណពូច្រើនដែលបានផ្តល់ពេលវេលាសំណេះសំណាលទាក់ទងនឹងជីវិតរបស់ផ្ទាល់របស់ពូតាំងពីជំនាន់បីឆ្នាំ ក្រោយម៉ោ៧៩សម័យតស៊ូហើយក្រោយម៉ោសម័យសមារណកម្មហ្នឹង ខ្ញុំអរគុណពូច្រើន!

ជឿន៖ បាទ!

«ចប់»